# ធនាគារជាតិ នៃ កម្ពុជា

## ព្រឹត្តិបត្រប្រចាំត្រីមាស



## លេខ ៤២

## ត្រីមាសទី៣ ឆ្នាំ២០១៣

ចេញផ្សាយតាមប្រកាសលេខ ធ៦-០១១-១២៣ ប្រ.ក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១១

បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា

អាសយដ្ឋាន : ២២-២៤ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រ : ២៥

ទូរស័ព្ទ : (៨៥៥) ២៣ ៧២២ ៥៦៣

ទូរសារ : (៨៥៥) ២៣ ៤២៦ ១១៧

គេហទំព័រ : www.nbc.org.kh

*********

Published by

# National Bank of Cambodia

Address : 22-24 Preah Norodom Blvd.
Phnom Penh, Cambodia

P.O.BOX : 25

Phone : (855) 23 722 563

FAX : (855) 23 426 117

Website : www.nbc.org.kh

គណៈកម្មការព្រឹត្តិបត្រ

- ឯកឧត្តម ថា យ៉ាវ ប្រធាន
- ឯកឧត្តម ស៊ុំ សន្និសិទ្ធ និពន្ធនាយក

Review Commission

- H.E. Tha Yao — Chairman
- H.E. Dr.Sum Sannisith — Chief Editor

# អារម្ភកថា



**ឯកឧត្តម ជា ចាន់តូ**
**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

*ប្រិយមិត្តអ្នកអានជាទីមេត្រី !*

នៅក្នុងត្រីមាសទី៣នេះ ប្រជាជនកម្ពុជាទូទាំងប្រទេសមានមោទនភាពក្រៃលែងដោយបានជ្រើសរើសតំណាងរបស់ខ្លួន តាមរយៈការបោះឆ្នោតនីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រកបដោយសេរី ត្រឹមត្រូវ យុត្តិធម៌ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ រាជរដ្ឋាភិបាលអាណត្តិទី៥ ត្រូវបានប្រសូត្រឡើងដោយមាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ស្របតាមឆន្ទៈរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស ដើម្បីបន្តដឹកនាំនាវាកម្ពុជាឆ្ពោះទៅកាន់ការរីកចម្រើនត្រចះត្រចង់ថែមទៀត ។

ស្ថិតក្នុងបរិការដែលកម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងភាពរឹងមាំនៃមូលដ្ឋានសេដ្ឋកិច្ច សកម្មភាពសេដ្ឋកិច្ចបានបន្តកើនឡើងនៅត្រីមាសទី៣នេះ ដែលនឹងគាំទ្រកំណើនសេដ្ឋកិច្ចអាចឲ្យសម្រេចបានតាមការគ្រោងទុកក្នុងអត្រា ៧,៦% នៅឆ្នាំ២០១៣នេះ ទោះជាសេដ្ឋកិច្ចសកលនៅមានភាពទន់ខ្សោយ និងទីផ្សារហិរញ្ញវត្ថុអន្តរជាតិនៅមានភាពមិនច្បាស់លាស់ក៏ដោយ ។ កំណើនសេដ្ឋកិច្ចកម្ពុជាបន្តគាំទ្រដោយកំណើនក្នុងវិស័យកសិកម្ម ការនាំចេញ ទេសចរណ៍ និងសំណង់និងអចលនទ្រព្យ ។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយប្តូរប្រាក់ប្រកបដោយភាពទន់ភ្លន់ និងប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជាបានរួមចំណែកយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ជាក់ស្តែង អត្រាអតិផរណាត្រូវបានរក្សាឱ្យស្ថិតនៅកម្រិតទាបប្រមាណ ៣% ហើយអត្រាប្តូរប្រាក់មានស្ថិរភាពល្អប្រសើរក្នុងរង្វង់ ៤.០៨៨ រៀលក្នុងមួយដុល្លារ ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងស្ថិរភាពនិងអភិវឌ្ឍវិស័យធនាគារឱ្យកាន់តែរីកចម្រើនស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។ បណ្តាញប្រព័ន្ធធនាគារបានបន្តកើនឡើងជាលំដាប់ ហើយបានផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយនៅទូទាំងប្រទេស ។ នៅត្រីមាសនេះ ធនាគារបរទេសថ្មី ២ បានបើកដំណើរការជាផ្លូវការនៅកម្ពុជា ហើយបានរួមចំណែកក្នុងការអភិវឌ្ឍវិស័យធនាគារកម្ពុជា ។ ជាក់ស្តែង ទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារបានកើនឡើងជាបន្តបន្ទាប់ដល់ ៧៦,៥% នៃផ.ស.ស ឥណទានចំពោះវិស័យឯកជននិងប្រាក់បញ្ញើកើនដល់ ៤៣% និង ៤១% នៃផ.ស.ស រៀងគ្នា ។ ចំណែកឯវិស័យមីក្រូហិរញ្ញវត្ថុបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ស្របតាមផែនការរបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍

(Millennium Development Goals) ។ គិតត្រឹមចុងត្រីមាសនេះ ទ្រព្យសកម្មរបស់វិស័យនេះ បានកើនឡើងដល់ប្រមាណ ១១% នៃទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារសរុប ធៀបនឹង ៩% ក្នុងគ្រាដូចគ្នាឆ្នាំ២០១២ ។ ជារួមប្រព័ន្ធធនាគារកម្ពុជាមានសុខភាពល្អប្រសើរដោយអនុបាតសាធនភាព និងអនុបាតសន្ទនីយភាព ស្ថិតនៅកម្រិតខ្ពស់សមស្រប ហើយអនុបាតឥណទានមិនដំណើការធៀបនឹងឥណទានសរុបមានកម្រិតទាប ដែលបង្ហាញថាផលប័ត្រឥណទានចំពោះវិស័យឯកជនរបស់ប្រព័ន្ធធនាគារមានភាពល្អប្រសើរ ។ ទន្ទឹមនេះ ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពត្រួតពិនិត្យ និងធានាឱ្យបានភាពរឹងមាំនៃប្រព័ន្ធធនាគារកម្ពុជា ធនាគារជាតិនៃកម្ពុជាបានពង្រឹងក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិ និងបានបង្កើតគណៈកម្មការសំខាន់ចំនួនបី ៖ ១) គណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ២) គណៈកម្មការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ៣) គណៈកម្មការប្រតិបត្តិគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុប្រកបដោយចីរភាព ជាពិសេសការពង្រឹងការគ្រប់គ្រងការិយាល័យឥណទាន ការធ្វើទំនើបកម្មប្រព័ន្ធផាត់ទាត់ជាតិ និងការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ ។ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៣នេះ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយមូលបត្រប្រាក់បញ្ញើអាចជួញដូរបាន (NCD) ក្នុងគោលបំណងបង្កើនជម្រើសនៃការរក្សាទ្រព្យសកម្មសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្តល់លទ្ធភាពទទួលបានសន្ទនីយភាពក្នុងទីផ្សារអន្តរធនាគារ និងអភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុផ្អែកតាមយន្តការទីផ្សារ ។

លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តកែលម្អ និងសាងសង់អគារសាខាធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ សម្រួលចរាចរណ៍រូបិយវត្ថុ និងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។ អគារសាខាថ្មីធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៣ បន្ទាប់ពីបានសម្ពោធដាក់ឱ្យប្រើប្រាស់នូវអគារសាខាថ្មីធនាគារជាតិនៃកម្ពុជាខេត្តបាត់ដំបង កាលពីដើមឆ្នាំនេះ ។

ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ជាប្រចាំលើការពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិក តាមរយៈការបណ្តុះបណ្តាល ការផ្ទេរចំណេះដឹង តាមរយៈការចូលរួមនិងរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា នៅក្នុងស្រុកនិងបរទេស ។ ទន្ទឹមនេះ កិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីក៏ត្រូវបានបន្តពង្រឹងនិងពង្រីកជាប្រចាំ ដើម្បីផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មាន ទទួលបានជំនួយបច្ចេកទេស និងពង្រឹងកិត្យានុភាពរបស់កម្ពុជានៅក្នុងតំបន់និងពិភពលោក ។ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៣ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាលើកទី៧ ស្តីពី សេរីភាវូបនីយកម្មគណនីមូលធននិងការគ្រប់គ្រងលំហូរមូលធនរបស់មជ្ឈមណ្ឌលស៊ាសិន ដែលសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការរូបិយវត្ថុក្នុងតំបន់អាស៊ីរបស់ធនាគារកណ្តាលជប៉ុន នៅខេត្តសៀមរាប ដោយជោគជ័យ ។

សរុបមក លទ្ធផលដ៏ល្អប្រសើរទាំងនេះ បានស្តែងឱ្យឃើញពីជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជាក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រការរីកចម្រើននៃសេដ្ឋកិច្ចប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជាជាលំដាប់ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ខ្ញុំសង្ឃឹមថា បន្ទាប់ពីបានអានព្រឹត្តិបត្រលេខ៤២នេះ ប្រិយមិត្តអ្នកអានទាំងអស់នឹងអាចទទួលបាននូវព័ត៌មានជាច្រើនទាក់ទងនឹងសកម្មភាពការងាររបស់ធនាគារជាតិនៃកម្ពុជា និងស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធធនាគារកម្ពុជាក្នុងត្រីមាសទី៣ ឆ្នាំ២០១៣នេះ ។ ក្នុងព្រឹត្តិបត្រចេញផ្សាយលើកនេះដែរ ក៏មានដាក់បញ្ចូលនូវ

បទឧទ្ទេសនាមស្តីពី ការវិភាគលើការគ្រប់គ្រងបំណុលសាធារណៈ ដែលលើកឡើងពីស្ថានភាពបញ្ហាប្រឈម និងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលរបស់ពិភពលោក ដើម្បីរួមចំណែកផ្តល់ជាព័ត៌មាន និងចំណេះដឹងដល់ប្រិយមិត្តអ្នកអាន ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានសហការ និងរួមចំណែកសម្រេចបាននូវសមិទ្ធផលនាពេលកន្លងមក ហើយខ្ញុំសង្ឃឹមថាប្រពៃណីដ៏ល្អនេះ នឹងបន្តនាំមកនូវសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងពេលអនាគត ។

ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជូនដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមប្រកបតែសេចក្តីសុខ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**

# មាតិកា

ទំព័រ


- អារម្ភកថា ........................................................................................ i-iii
- សេចក្ដីប្រកាសព័ត៌មានស្ដីពីការចេញផ្សាយមូលបត្រអាចជួញដូរបាន ដោយធនាគារជាតិនៃកម្ពុជា........................................................................ ១
- និតិវិធីក្នុងការជាវមូលបត្រអាចជួញដូរបាន ដោយធនាគារជាតិនៃកម្ពុជា....... ២
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបើក និងបិទសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា........................ ៦
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងសន្និសីទ លើកទី៩ ស្ដីពី ការគ្រប់គ្រងបំណុល (ភាសាអង់គ្លេស និងខ្មែរ)....... ២១
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជាថ្លែងក្នុងពិធីអបអរសាទរភាពជាដៃគូរវាងធនាគារសហពាណិជ្ជ និងធនាគារ E.SUN (ភាសាខ្មែរនិងអង់គ្លេស)......................................................... ៣២
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺ................................................................................ ៣៨
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការ ធនាគារហុងលីអុង (ខេមបូឌា) ភីអិលស៊ី (ខ្មែរនិងភាសាអង់គ្លេស)...................................................... ៤៣

- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីបើកសិក្ខាសាលាលើកទី៧ នៃមជ្ឈមណ្ឌល SEACEN ស្តីពីសេរីភាវូបនីយកម្មគណនីមូលធននិងការគ្រប់គ្រងលំហូរមូលធន (ភាសាអង់គ្លេសនិងខ្មែរ)...... ៤៩
- តារាងអត្រាប្តូរប្រាក់ប្រចាំខែ ............................................................. ៥៧
- តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ (ភាសាខ្មែរនិងអង់គ្លេស) .................... ៥៨
- តារាងអត្រាការប្រាក់លើប្រាក់កម្ចី (ភាសាខ្មែរនិងអង់គ្លេស)........................ ៦០
- បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ភាសាខ្មែរនិងអង់គ្លេស) .......... ៦២
- ប្រព័ន្ធធនាគារកម្ពុជា (ភាសាខ្មែរនិងអង់គ្លេស) ...................................... ១០២
- រូបថតសកម្មភាពថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា.................................. ១០៤-១១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការចេញផ្សាយមូលបត្រអាចជួញដូរបាន ដោយធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយមូលបត្រអាចជួញដូរបាន ដែលគ្រឹះស្ថានធនាគារអាចនឹងប្រើប្រាស់ចាប់ពីថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៣ នេះតទៅ ។ ការចេញផ្សាយនេះគឺជាផ្នែកមួយនៃកំណែទម្រង់ និងការអភិវឌ្ឍជាបន្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០ របស់រាជរដ្ឋាភិបាល ក្នុងគោលបំណង (i) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងទីផ្សាររូបិយវត្ថុ នៅលើមូលដ្ឋានប្រកប ដោយសុវត្ថិភាព (ii) ផ្តល់ដល់គ្រឹះស្ថានធនាគារនូវឧបករណ៍មួយថ្មីទៀតសម្រាប់គ្រប់គ្រងសន្ទនីយភាពជាបន្ថែមលើប្រាក់បញ្ញើមានកាលកំណត់ដែលមានស្រាប់ និង (iii) បង្កើតឧបករណ៍នយោបាយរូបិយវត្ថុសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ប្រកបដោយប្រសិទ្ធភាព ។ មូលបត្រអាចជួញដូរបាននេះ មានរូបភាពជាប័ណ្ណប្រាក់បញ្ញើអាចជួញដូរបាន (Negotiable Certificate of Deposits) និងជាឧបករណ៍ហិរញ្ញវត្ថុរយៈកាលខ្លីដែលម្ចាស់មូលបត្រអាចប្រើប្រាស់ដើម្បីដោះស្រាយកង្វះខាតសន្ទនីយភាពបណ្តោះអាសន្ន ក្រោមរូបភាពជាការលក់ ដាក់បញ្ចាំ និងធ្វើជាវត្ថុធានាការខ្ចីចងការ ឬប្រតិបត្តិការទទួលទិញវិញ (Repurchase Agreement) ។

ភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

## នីតិវិធីក្នុងការជាវមូលបត្រអាចជួញដូរបាន ដោយធនាគារជាតិនៃកម្ពុជា

**១. គោលបំណង**

ឯកសារនេះរៀបចំឡើងក្នុងគោលបំណងផ្តល់ការយល់ដឹងដល់អ្នកជាវ អំពីនីតិវិធីក្នុងការជាវមូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposit, NCD) ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។

**២. អ្នកមានសិទ្ធិជាវ** NCD:

បណ្តាអង្គភាពដែលទទួលបានសិទ្ធិជាវ NCD គឺគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**៣. នីតិវិធីជាវ:**

៣.១. ទីកន្លែង: ការដាក់ពាក្យសុំជាវ ផ្ទេរកម្មសិទ្ធិ និងទំនាក់ទំនងទូទៅពាក់ព័ន្ធនឹង NCD នឹងប្រព្រឹត្តទៅនៅការិយាល័យគ្រប់គ្រងមូលបត្រ នាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា។

៣.២. ពេលវេលា: រៀងរាល់ថ្ងៃធ្វើការ ចាប់ពីម៉ោង ៨ព្រឹក ដល់ម៉ោង ៣រសៀល។ ចំពោះការដាក់ពាក្យសុំក្រោយម៉ោង ១១ព្រឹក នោះប្រតិបត្តិការពាក់ព័ន្ធនឹងត្រូវអនុវត្តនៅថ្ងៃធ្វើការបន្ទាប់។

៣.៣. ការសុំជាវ:

៣.៣.១. អ្នកជាវ NCD ត្រូវបំពេញពាក្យសុំជាវតាមទម្រង់គំរូលេខ NBC-NCD002 ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២។

៣.៣.២. ការទូទាត់លើការជាវ NCD អាចធ្វើឡើងតាមរយៈមូលប្បទានបត្ររបស់ធនាគារជាតិនៃកម្ពុជា ឬបញ្ជាទូទាត់ផ្សេងទៀតដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។

៣.៣.៣. ធនាគារជាតិនៃកម្ពុជានឹងចុះបញ្ជីទូទាត់ និងដាក់ផ្ញើ NCD នៅក្នុងគណនីបញ្ញើមូលបត្រ រួចចេញផ្សាយលិខិតបញ្ជាក់អំពីកម្មសិទ្ធិភាពនៃ NCD តាមទម្រង់គំរូ NBC-NCD004 ដូចមានក្នុងឧបសម្ព័ន្ធ៤ ជូន អតិថិជនតាមពេលដែលបានកំណត់ខាងលើ។

**៤. ការបើកគណនីបញ្ញើមូលបត្រ:**

NCD ត្រូវបានចេញផ្សាយជាទម្រង់អរូបិយ ដែលត្រូវតែរក្សាទុកក្នុងគណនីបញ្ញើមូលបត្រនៅធនាគារជាតិនៃកម្ពុជា។ ហេតុនេះ អ្នកជាវ NCD ទាំងអស់ ចាំបាច់ត្រូវបើកគណនីបញ្ញើមូលបត្រនៅធនាគារជាតិនៃ កម្ពុជា។

៤.១. ការស្នើសុំបើកគណនីបញ្ញើមូលបត្រ ត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចមានចែងក្នុងទម្រង់គំរូ NBC-NCD 001 និងគំរូហត្ថលេខា (Specimen of Signatures) ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១។

៤.២. ការិយាល័យគ្រប់គ្រងមូលបត្រនឹងបើកគណនីបញ្ជីមូលបត្រជូនអ្នកជាវ NCD នៅពេលទទួលបានឯកសារគ្រប់គ្រាន់។

## ៥. អត្រាការប្រាក់:

៥.១. អត្រាការប្រាក់ចំពោះ NCD នឹងមានចេញផ្សាយជារៀងរាល់ថ្ងៃធ្វើការនៅក្នុងគេហទំព័ររបស់ NBC (www.nbc.org.kh)។

៥.២. ការប្រាក់ត្រូវបានគណនាផ្អែកលើចំនួនថ្ងៃជាក់ស្តែងនៃឆ្នាំនីមួយៗ (៣៦៥ ឬ ៣៦៦ថ្ងៃក្នុងមួយឆ្នាំ)។

## ៦. ការផ្ទេរកម្មសិទ្ធិនៃ NCD

៦.១. ភាគីប្រគល់ និងទទួល NCD ត្រូវបំពេញពាក្យស្នើសុំផ្ទេរកម្មសិទ្ធិ NCD និងប្រគល់ជូនមកធនាគារជាតិនៃកម្ពុជារៀងៗខ្លួន តាមទម្រង់គំរូ NBC- NCD005 ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៥ ។

៦.២. បន្ទាប់ពីទទួលបានពាក្យស្នើសុំផ្ទេរកម្មសិទ្ធិពី ភាគីប្រគល់ និងទទួល NCD ធនាគារជាតិនៃកម្ពុជានឹងធ្វើការផ្ទៀងផ្ទាត់ពាក្យស្នើសុំផ្ទេរកម្មសិទ្ធិទាំងពីរ រួចចុះបញ្ជីផ្ទេរសិទ្ធិកាន់កាប់ NCD ពីគណនីបញ្ជីមូលបត្ររបស់ភាគីប្រគល់ទៅគណនីបញ្ជីមូលបត្ររបស់ភាគីទទួល និងចេញផ្សាយសេចក្តីជូនដំណឹងស្តីពីការផ្ទេរកម្មសិទ្ធិ NCD តាមទម្រង់គំរូ NBC-NCD 006 ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៦ ជូនភាគីពាក់ព័ន្ធតាមពេលដែលបានកំណត់ខាងលើ។

៦.៣. ដើម្បីធានាសុវត្ថិភាពដល់អ្នកចូលរួមក្នុងទីផ្សារអន្តរធនាគារ ការទូទាត់ត្រូវតែអនុវត្តតាមរយៈធនាគារជាតិនៃកម្ពុជាហើយប្រតិបត្តិការផ្ទេរកម្មសិទ្ធិនឹងត្រូវអនុវត្តទន្ទឹមគ្នានឹងការទូទាត់ប្រាក់ (Delivery versus Payment)។

## ៧. ការទូទាត់នៅកាលវសាន

៧.១. នៅកាលវសាននៃ NCD ធនាគារជាតិនៃកម្ពុជានឹងធ្វើប្រតិបត្តិការផ្ទេរប្រាក់ដើម និងការប្រាក់ទៅក្នុងគណនីចរន្តរបស់ម្ចាស់កម្មសិទ្ធិចុងក្រោយ (Ultimate NCD holder)។

៧.២. ម្ចាស់កម្មសិទ្ធិចុងក្រោយនៃ NCD នឹងទទួលបានប្រកាសឥណទានពីធនាគារជាតិនៃកម្ពុជាអំពីលទ្ធផលនៃការផ្ទេរនេះ។

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number.................................................

*Unofficial translate*

# Procedures in subscribing NCD issued by NBC

**1. Purpose**

This document is intended to provide the subscriber a clear understanding about the subscription procedure for the Negotiable Certificate of Deposit (NCD) issued by the National Bank of Cambodia (NBC).

**2. Eligible subscribers**

Eligible subscribers are banks and financial institutions as stated in the Law on Banking and Financial Institutions.

3. **Subscribing procedures**

3.1. **Location:** The submission to subscribe NCD, request for ownership transfer and other inquiries relating to NCD will be taken place at the Securities Management Division, Banking Operation Department, NBC.

3.2. **Time:** Every working day from 8:00AM to 3:00PM. In case the submission is done after 11:00 AM, its related transactions will be executed on the next working day.

**3.3. Subscribing the NCD:**

3.3.1. The subscriber shall fill out the application form (NBC-NCD002) as attached in the appendix 2.

3.3.2. The payment for NCD shall be made by NBC's check or other means of payment order accepted by NBC.

3.3.3. NBC will deduct the fund from subscriber's account, issue, and deposit the NCD in subscriber's custodian account and then handover the ownership confirmation (form NBC-NCD004 as attached in the appendix 4) to the subscriber according to the time stated above.

**4. The opening of Custodian Account**

NCD is issued in dematerialized form which shall be deposited at NBC. Therefore, all subscribers are required to open a custodian account at NBC.

4.1. The application to open the custodian account shall be submitted along with relating documents as mentioned in NBC-NCD 001 form and the specimen of signature as attached in the appendix 1.

4.2. The Securities Management Division will open the custodian account for the subscriber as soon after the required documents are completed.

**5. Interest Rate**

5.1. The interest rate for NCD is quoted on every working day on the NBC's website: www.nbc.org.kh.

5.2. The interest amount will be calculated based on the actual day in each year (365 or 366days per year).

**6. Ownership Transfer**

6.1. The delivering and receiving parties of NCD shall fill out the application for ownership transfer (form NBC-NCD 005 attached in the appendix 5) and deliver to NBC separately.

6.2. After receiving the requests for ownership transfer from both parties, NBC will match the information in both requests and transfer the NCD from custodian account of delivering party to that of receiving party and will inform the result of ownership transfer (form NBC-NCD 006 as attached in the appendix 6) to the concerned parties according to the time mentioned above.

6.3. To ensure the safety for the participants in interbank market, the payment shall be carried out through NBC and the delivery of NCD shall be executed at the same time as the payment is done (Delivery versus Payment).

**7. Redemption**

7.1. On maturity date, the NBC will transfer the principal and interest amount to the current account of ultimate NCD holder.

7.2. The ultimate NCD holder will receive the credit advice from NBC as a result of this transaction.

ធនាគារជាតិ នៃ កម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ.....................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា
## នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣

**សូមគោរព :**

- គណៈអធិបតី
- លោក Robert Beerens ជំនាញការនៅធនាគារជាតិនៃកម្ពុជា
- លោក Ye-Hong Ahn ជំនាញការធនាគារកណ្តាលកូរ៉េ នៅធនាគារជាតិនៃកម្ពុជា
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជាជាមួយលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា នាពេលនេះ ។ ជារៀងរាល់ឆ្នាំ ធនាគារជាតិនៃកម្ពុជាយើងតែងតែរៀបចំប្រារព្ធពិធីនេះឡើង ដើម្បីផ្សព្វផ្សាយនិងអបអរសាទរចំពោះលទ្ធផលការងាររបស់ខ្លួនដែលសម្រេចបាន ។ សន្និបាតរបស់យើងថ្ងៃនេះ ត្រូវបានរៀបចំឡើងបន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នៃរដ្ឋសភា កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣ បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងព្រមទាំងទទួលស្គាល់ដោយអ្នកអង្កេតការជាតិ-អន្តរជាតិ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរយ៉ាងខ្លាំង ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ កសាងសមិទ្ធផលជាច្រើនជូនធនាគារជាតិនៃកម្ពុជា និងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើន ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ស្របតាម យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ខ្ញុំសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីលទ្ធផលការងារសំខាន់ៗ របស់ធនាគារជាតិនៃកម្ពុជានៅឆមាសទី១ ឆ្នាំ២០១៣ ដូចតទៅ ៖

**I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា**

តាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅឆមាសទី១ ឆ្នាំ២០១៣ សេដ្ឋកិច្ចពិភពលោកនៅតែបន្តកើនឡើងក្នុងល្បឿនយឺត ដោយសារការមិនទាន់ងើបឡើងវិញនៃសេដ្ឋកិច្ចតំបន់អឺរ៉ូ កំណើនយឺតនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងសន្ទុះកំណើននៃប្រទេសកំពុងងើបឡើងសំខាន់ៗមួយចំនួនដូចជា ប្រទេសចិននិងឥណ្ឌា បានទទួលរងស្ថានភាពចុះទន់ខ្សោយនៃតម្រូវការទាំងក្នុងនិងក្រៅប្រទេស ។ ប៉ុន្តែ ដំណើរការសេដ្ឋកិច្ចពិភពលោកនៅឆមាសទី២ ត្រូវបានរំពឹងថា មានភាពប្រសើរជាងឆមាសទី១ បន្តិច ។

ស្ថិតក្នុងស្ថានភាពនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើការព្យាករកំណើនសេដ្ឋកិច្ចពិភពលោក មកត្រឹម ៣,១% នៅឆ្នាំ២០១៣ ស្មើនឹងអត្រាឆ្នាំ២០១២ ដែរ ។ ក្នុងនោះ កំណើនសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍នឹងកើន ១,២% ហើយប្រទេសកំពុងងើបឡើងនិងប្រទេសកំពុងអភិវឌ្ឍន៍នឹងមានកំណើន ៥% ។ ដោយឡែក សេដ្ឋកិច្ចប្រទេសអាស៊ាន ៥ នឹងរក្សាកំណើនខ្ពស់ប្រមាណ ៥,៦%។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ បានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ។ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ បានបន្តបង្ហាញសញ្ញាល្អប្រសើរ ដោយការនាំចេញ វិស័យទេសចរណ៍ និងកសិកម្មមានកំណើនរឹងមាំ ហើយវិស័យអចលនទ្រព្យនិងសំណង់បានងើបឡើងជាលំដាប់ ។ ផ្អែកលើស្ថានភាពល្អប្រសើរនេះ រាជរដ្ឋាភិបាលបានព្យាករដោយសុទិដ្ឋិនិយមថា សេដ្ឋកិច្ចកម្ពុជា នឹងមានកំណើនប្រមាណ ៧,៦% ក្នុងឆ្នាំ២០១៣នេះ ហើយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយចំនួនក៏បានកែប្រែការព្យាករលើកំណើនសេដ្ឋកិច្ចកម្ពុជាខ្ពស់ជាងមុនផងដែរ ។ កំណើននេះគាំទ្រដោយវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស គួបផ្សំនឹងការអនុវត្តគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មវិស័យផលិតកម្ម ជាពិសេស វិស័យកសិកម្ម និងពិពិធកម្មទីផ្សារនាំចេញផង ពិតជាបានរួមចំណែកគាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ។

ទន្ទឹមនេះ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយប្តូរប្រាក់ប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្ន ដោយផ្អែកលើវឌ្ឍនភាពនៃសកម្មភាពសេដ្ឋកិច្ចជាតិនិងបម្រែបម្រួលនៃសេដ្ឋកិច្ចពិភពលោក ។

## II/- លទ្ធផលការងារសំខាន់ៗដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន

ដើម្បីរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃប្រកបដោយប្រសិទ្ធភាពដោយរក្សាបាននូវស្ថិរភាពនៃតម្លៃប្រាក់រៀល និងអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក និងគ្រប់គ្រងអត្រាអតិផរណាឱ្យមានកម្រិតទាប ប្រែប្រួលក្នុងកម្រិតមួយអាចគ្រប់គ្រងបាន ។ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាស្ថិរភាពល្អប្រសើរសម្រាប់គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ។

សមិទ្ធផលទាំងនេះ អាចឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗដូចខាងក្រោម ៖ នៅក្នុងឆមាសទី១ ឆ្នាំ២០១៣នេះ បើគិតជាមធ្យមក្នុងរយៈពេល ៦ខែ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារបានឡើងថ្លៃប្រមាណ ០,៧% ធៀបនឹងគ្រាដូចគ្នាក្នុងឆ្នាំ២០១២ ។ ចំណែកអតិផរណារួមឆ្នាំលើឆ្នាំនាដំណាច់ឆមាសទី១នេះ ស្មើនឹង ២,៩% ធៀបនឹង ១,៨% នៅគ្រាដូចគ្នាឆ្នាំ២០១២ ។ ជារួម អតិផរណាស្ថិតក្នុងកម្រិតទាបក្រោម ៣% ដែលជាកម្រិតមួយអាចគ្រប់គ្រងបាន ។ រូបិយវត្ថុទូទៅ(M2)មានកំណើនឆ្នាំលើឆ្នាំ ១១% ដោយភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុមានកម្រិតប្រមាណ ៥៣% នៅខែមិថុនា ឆ្នាំ២០១៣ ធៀបនឹង ៤៩% នាគ្រាដូចគ្នានៅឆ្នាំមុន ដែលឆ្លុះបញ្ចាំងពីតួនាទីនៃវិស័យធនាគារដែលកាន់តែមានសារៈសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងរហូតដល់ ៤.០៤៦ លានដុល្លារអាមេរិក កើនឡើង ១៣,៤% ធៀបនឹងឆមាសទី១ ឆ្នាំ២០១២ ដែលអាចធានាការនាំចូលបានចំនួនប្រមាណ ៤ខែ ។ ការគ្រប់គ្រងទុនបម្រុងត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន ស្របតាមភាពរឹងមាំនៃមូលដ្ឋានសេដ្ឋកិច្ចជាតិ ។ ស្ថិរភាពថ្លៃ និងតម្លៃប្រាក់រៀលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនទូទៅចំពោះសេដ្ឋកិច្ចកម្ពុជា ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរ ដូចខាងក្រោម ៖

**១/-វិស័យធនាគារ:** វិស័យនេះមានការអភិវឌ្ឍ និងរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងវិសាលភាព និងទំហំប្រតិបត្តិការ និងបានដើរតួនាទីកាន់តែសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ផ្នែកវិសាលភាពនាពេលបច្ចុប្បន្ននេះ ធនាគារពាណិជ្ជមានចំនួន ៣៤ ធនាគារឯកទេសចំនួន ៧ ការិយាល័យតំណាងធនាគារបរទេស ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣៧ ក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ ត្រូវបានអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជន ប្រតិបត្តិករឥណទាន

ជនបទដែលបានចុះបញ្ជីចំនួន ៣៤ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ១ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា១ និងអ្នកដំណើរការតតិយភាគី ៤ ។

ចំពោះទំហំប្រតិបត្តិការវិញ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារបានកើនឡើង ២៥,៦% និងឥណទានដល់វិស័យឯកជនបានកើនឡើង ៣២,៧%ធៀបនឹងគ្រាដូចគ្នានៅឆ្នាំ២០១២ ។ ការវិវត្តរីកចម្រើននេះគួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្នផងនោះ បានធ្វើឱ្យឥណទានមិនដំណើរការ(NPL)ថយចុះមកនៅកម្រិត ២,៣% ដែលបង្ហាញពីគុណភាពល្អនៃទ្រព្យសកម្មរបស់វិស័យធនាគារ ។ ដើម្បីរក្សាបាននិរន្តរភាពនៃការអភិវឌ្ឍប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានលើកកម្ពស់ជាប្រចាំនូវសមត្ថភាពនិងវិធីសាស្ត្រត្រួតពិនិត្យនិងវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ។

**២/- វិស័យមីក្រូហិរញ្ញវត្ថុ** : មានការរីកចម្រើនយ៉ាងខ្លាំង ត្រូវបានគេចាត់ទុកថាជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ឥណទានផ្តល់ដោយវិស័យមីក្រូហិរញ្ញវត្ថុបានបន្តកើនឡើងគួរឲ្យកត់សម្គាល់ ដោយសមតុល្យឥណទានសរុបកើនឡើងដល់ ៤.៤១២,៣ ពាន់លានរៀល ដែលត្រូវបានផ្តល់ដល់អតិថិជនចំនួនជាង ១,៣ លាននាក់ ពោលគឺកើនឡើង ២៤,៧% និង ១,៤% រៀងគ្នាធៀបនឹងរយៈពេលដូចគ្នា ។ ប្រាក់បញ្ញើវិញបានកើនដល់ ១.៦៦២,៤ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ១,១លាននាក់ ពោលគឺកើនឡើង ៥២% និង ៦០,២ រៀងគ្នា ។ ការរីកចម្រើននេះបានរួមចំណែកអភិវឌ្ឍអាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។

**៣/- ការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** : ខណៈដែលវិស័យហិរញ្ញវត្ថុមានភាពប្រទាក់ក្រឡាគ្នានិងប្រឈមនឹងហានិភ័យនៃវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិកម្ម បានពង្រឹងការត្រួតពិនិត្យសុខភាពគ្រឹះស្ថានធនាគារជាប់ជាប្រចាំ តាមរយៈការចុះទៅត្រួតពិនិត្យដល់ទីកន្លែងនិងត្រួតពិនិត្យលើឯកសារ ក្នុងបំណងដើម្បីជួយពង្រឹងអភិបាលកិច្ចល្អនិងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ ។ គិតត្រឹមឆមាសទី១ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែង ចំពោះធនាគារពាណិជ្ជចំនួន ៧ ធនាគារឯកទេសចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៤ និងប្រតិបត្តិករឥណទានជនបទចំនួន១ ។

ជារួម យើងបានពិនិត្យឃើញថា ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារមានភាពល្អប្រសើរនិងគោរពតាមវិធានការប្រុងប្រយ័ត្ន ក្នុងនោះ អនុបាតសាធនភាពជាមធ្យមមានប្រមាណ ២៦% លើសពីកម្រិតតម្រូវការអប្បបរមា ១៥% ហើយអនុបាតសន្ទនីយភាពមានចំនួន ៨២,២% លើសពីកម្រិតតម្រូវការអប្បរមា ៥០% ។ ចំពោះគ្រឹះស្ថានធនាគារមួយចំនួនដែលមានចំណុចខ្វះខាត យើងបានផ្តល់អនុសាសន៍ដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយតាមស្ថានភាពជាក់ស្តែងផងដែរ ។

**៤/-ការពង្រឹងអភិបាលកិច្ចល្អ:** ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចឱ្យស្របតាមគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង តាមរយៈការបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា ដាក់ចេញនូវបទប្បញ្ញត្តិនានា និងបណ្តុះបណ្តាលសមត្ថភាពជំនាញរបស់មន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ។ ជាក់ស្តែង នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចេញផ្សាយរបាយការណ៍សវនកម្មរបស់សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ចាម ។ ជាមួយគ្នានេះដែរ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក៏បានចេញផ្សាយរបាយការណ៍សវនកម្មសម្រេច និងសេចក្តីសង្ខេបរបាយការណ៍នៅខុទ្ទកាល័យលើការងារគ្រប់គ្រងសម្ភារៈការិយាល័យ និងនៅនាយកដ្ឋានប្រតិបត្តិការលើប្រតិបត្តិការផ្ទេរប្រាក់ ។

ចំពោះការងារអធិការកិច្ចវិញ យើងបានចុះត្រួតពិនិត្យនៅសាខាធនាគារជាតិនៃកម្ពុជាបានចំនួន ៥ ដោយផ្តោតជាសំខាន់ទៅលើការធានាសុវត្ថិភាពឃ្លាំងប្រាក់ ការគ្រប់គ្រងសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញ ដែលបានដាក់ចុះ ព្រមទាំងពង្រឹងគុណវុឌ្ឍិ វិន័យការងាររបស់មន្ត្រីបុគ្គលិក និងប្រសិទ្ធភាពការងារនៅតាមសាខាឱ្យកាន់តែប្រសើរ ។

**៥/- ការអភិវឌ្ឍទីផ្សារអន្តរធនាគារ** : បច្ចុប្បន្ន យើងកំពុងរៀបចំយន្តការអនុវត្តតាមលក្ខណៈបច្ចេកទេស បណ្តុះបណ្តាលធនធានមនុស្ស កសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងមូលដ្ឋានគតិយុត្តិជាដើម ខណៈដែលទីផ្សារមូលបត្រនិងទីផ្សារទុននៅកម្ពុជាបានដំណើរការនាពេលថ្មីៗនេះ ដើម្បីបង្កើនជំនឿទុកចិត្ត និងឱ្យគ្រឹះស្ថានធនាគារ និងធនាគារខ្ចីគ្នានៅពេលដែលជួបបញ្ហាខ្វះខាតសន្ទនីយភាព ។

**៦/- ការអភិវឌ្ឍប្រព័ន្ធជាតិទូទាត់:** បច្ចុប្បន្ន ប្រព័ន្ធទូទាត់នៅកម្ពុជាមានប្រព័ន្ធជាតិផាត់ទាត់ដែលបានដាក់ឲ្យដំណើរការកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ដែលអាចផាត់ទាត់ទាំងមូលបត្រ និងឧបករណ៍បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក ដូចជា ការផ្ទេរឥណទាន (Credit Remittance) ឥណទានផ្ទាល់ (Direct Credit) និងឥណពន្ធផ្ទាល់ (Direct Debit) ជាដើម។ ដើម្បីសម្រួលដល់កិច្ចដំណើរការផាត់ទាត់ឲ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានរៀបចំឯកសារវិធាន និងនីតិវិធីសភាផាត់ទាត់ជាតិសម្រាប់ជាគោលការណ៍មូលដ្ឋានក្នុងការប្រតិបត្តិ និងអនុវត្តរបស់សមាជិក និងសភាផាត់ទាត់ជាតិ ។

**៧/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : ដើម្បីបន្តអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ យើងបានពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់ខ្លួន ដោយបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា បណ្តុះបណ្តាលផ្នែកការងារប្រតិបត្តិការនិងជំនាញ IT និងរៀបចំការងារចាត់តាំងមន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ស្របតាមការងារជាក់ស្តែង ។ ក្រៅពីនេះ យើងបានបន្តតាមដានការអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) នៅតាម

សាខារាជធានី-ខេត្ត ព្រមទាំងបន្តបណ្តុះបណ្តាលធនធានមនុស្ស ទាំងផ្នែកបច្ចេកទេសនិងការងារគ្រប់គ្រងត្រូវបានពង្រឹង ដើម្បីពង្រឹងការអនុវត្តប្រព័ន្ធនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិជាលក្ខណៈទ្វេភាគីនិងពហុភាគីវិញ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ ហើយសម្រេចបានសមិទ្ធផលដូចតទៅ ៖

**១/- មូលនិធិរូបិយវត្ថុអន្តរជាតិ** (IMF) ៖ ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជាចំនួន ៣ លើក ។ លើកទី១ ជាបេសកកម្មជំនួយបច្ចេកទេសនៃនាយកដ្ឋានទីផ្សារមូលធននិងរូបិយវត្ថុ ចាប់ពីថ្ងៃទី១១-១៨ ខែមីនា ឆ្នាំ២០១៣ ដើម្បីសិក្សានិងវាយតម្លៃពីស្ថានភាពនៃស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជានាពេលបច្ចុប្បន្ន ។ លើកទី២ ជាបេសកកម្មរបស់មន្ត្រីមូលនិធិរូបិយវត្ថុអន្តរជាតិ ចាប់ពីថ្ងៃទី២២ ខែមេសា ដល់ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៣ ដើម្បីពិនិត្យឡើងវិញអំពីយុទ្ធសាស្ត្រសកម្មភាពការងារ ក្នុងការបន្តពង្រឹងគុណភាពចងក្រងស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិ តាមវិធីសាស្ត្រចងក្រងថ្មីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិដែលបានបោះផ្សាយលើកទី៦ ។ លើកទី៣ ចាប់ពីថ្ងៃទី៦-១០ ខែឧសភាឆ្នាំ២០១៣ ពិនិត្យការវិវត្តរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ច និងពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៅឆ្នាំ២០១៣ ដោយផ្តោតសំខាន់លើ (១).ទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ចក្នុងឆ្នាំ២០១៣ (២).គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ និងស្ថានភាពរូបិយវត្ថុ (៣).បញ្ហាទាក់ទងនឹងប្រតិបត្តិការរូបិយវត្ថុ និងវឌ្ឍនភាពក្នុងការពង្រឹងក្របខ័ណ្ឌរូបិយវត្ថុបច្ចុប្បន្ន (៤).ការងារទាក់ទងនឹងការត្រួតពិនិត្យធនាគារ ភាពរឹងមាំវិស័យហិរញ្ញវត្ថុ និងការប្រឆាំងការសម្អាតប្រាក់ (៥).ឥទ្ធិពលនៃលំហូរមូលធនលើប្រព័ន្ធធនាគារ និងស្ថិរភាពហិរញ្ញវត្ថុ (៦).វឌ្ឍនភាពនៃការចាប់ផ្តើមបង្កើតវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបាន និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និង (៧). ប្រធានបទទាក់ទងមាត្រាទី៤ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ឆ្នាំ២០១៣ ។

ជារួម អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានវាយតម្លៃល្អពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា ជាពិសេសចំពោះសមិទ្ធផលនានាដែលធនាគារជាតិនៃកម្ពុជាខិតខំរក្សាស្ថិរភាពថ្លៃ និងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុក្នុងរយៈពេលខ្លីនិងមធ្យមបានប្រសើរ និងបានជួយគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។

**២/-ធនាគារអភិវឌ្ឍន៍អាស៊ី**(ADB): ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេសសម្រាប់ពង្រឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ តាមរយៈការជួយរៀបចំឯកសារបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងផ្តល់ជំនួយគាំទ្រកម្មវិធីឥណទានសម្រាប់វិស័យហិរញ្ញវត្ថុជំហានទី៣ ដើម្បីធ្វើជាមាគ៌ាចង្អុលទិសអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែស៊ីជម្រៅ និងមានកម្រិត

សមាហរណកម្មខ្ពស់ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

៣/- **ក្រុមប្រទេសអាស៊ាន (ASEAN):** កិច្ចសហប្រតិបត្តិការអាស៊ាន និងអាស៊ាន+៣ បានដើរតួនាទីកាន់តែសំខាន់ខ្លាំងឡើងក្នុងការធ្វើសមាហរណកម្មហិរញ្ញវត្ថុរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទាក់ទាញការវិនិយោគ និងរក្សាស្ថិរភាពហិរញ្ញវត្ថុនៅក្នុងតំបន់ ។ តាមរយៈកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ប្រទេសជាសមាជិកបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍទីផ្សារមូលធនសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ សេរីភាវូបនីយកម្មគណនីដើមទុន និងវេទិកាទីផ្សារមូលធនអាស៊ាន ។

៤/- **មជ្ឈមណ្ឌល SEACEN :** កិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល SEACEN មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវទាក់ទងនឹងវិស័យហិរញ្ញវត្ថុ រូបិយវត្ថុ ធនាគារ និងការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ពង្រឹងសមត្ថភាពមន្ត្រីធនាគារកណ្តាលក្នុងតំបន់ ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំនានា ដែលរៀបចំដោយមជ្ឈមណ្ឌលស៊ាសិន សហការជាមួយធនាគារកណ្តាលជាសមាជិក ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលារបស់មជ្ឈមណ្ឌលស៊ាសិន ដោយសហការជាមួយមជ្ឈមណ្ឌលសិក្សាធនាគារកណ្តាលជប៉ុនលើកទី៧ ស្តីពីការគ្រប់គ្រងនយោបាយរូបិយវត្ថុនិងម៉ាក្រូសេដ្ឋកិច្ច ចាប់ពីថ្ងៃទី២៥ ខែមីនា ដល់ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ នៅខេត្តសៀមរាបប្រកបដោយជោគជ័យ។

៥/- **ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone) :** ប្រតិភូធនាគារជាតិនៃកម្ពុជាតែងតែបានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone) ជារៀងរាល់ឆ្នាំ ដើម្បីផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ក្នុងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាល ការដឹកនាំគោលនយោបាយរូបិយវត្ថុ និងការពង្រឹងកិច្ចសហប្រតិបត្តិការរូបិយវត្ថុ។ កាលពីថ្ងៃទី៨-១១ ខែឧសភា ឆ្នាំ២០១៣ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានអញ្ជើញទៅចូលរួមសន្និសីទប្រចាំឆ្នាំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង លើកទី២០ នៅទីក្រុងវ៉ៃសៃ ប្រទេសបារាំង ។

៦/- **សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA) :** ធនាគារជាតិនៃកម្ពុជាត្រូវបានមហាសន្និបាតជ្រើសតាំងជាប្រធានសមាគមនេះសម្រាប់អាណត្តិរយៈពេល២ឆ្នាំ ចាប់ពីខែមិថុនា ឆ្នាំ២០១២ ដល់ ខែមិថុនា ឆ្នាំ២០១៤ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកពាក់ព័ន្ធនឹងវិស័យមីក្រូហិរញ្ញវត្ថុនិងហិរញ្ញប្បទានជនបទ ។ ក្នុងនាមជាប្រធានសមាគម ធនាគារជាតិនៃកម្ពុជាបានដឹកនាំប្រកបដោយជោគជ័យនូវកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិលើកទី៦២ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ។

**៧/- កិច្ចសហប្រតិបត្តិការទ្វេភាគី** មានការរីកចម្រើនជាលំដាប់។ យើងបានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ កូរ៉េ បារាំង វៀតណាម ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ឆេកូ លុចហ្សំបួរ អាល្លឺម៉ង់ គណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ គណៈកម្មការបញ្ញត្តិកម្មធនាគារចិន អាជ្ញាធរបទប្បញ្ញត្តិប្រុងប្រយ័ត្នអូស្ត្រាលី និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ាននិងអាស៊ាន+៣ លើផ្នែកបណ្តុះបណ្តាលធនធានមនុស្សនិងផ្លាស់ប្តូរបច្ចេកទេស។

**- គណៈអធិបតី**

**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងឡាយដែលយើងសម្រេចបានសព្វថ្ងៃនេះ បានមកពីការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការចូលរួមសហការពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ដើម្បីជ្រាបពីសមិទ្ធផលលម្អិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍លម្អិតជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាជិកក្រុមប្រឹក្សាភិបាលនិងមន្ត្រីបុគ្គលិកទាំងអស់ដែលបានខិតខំប្រឹងប្រែងរួមចំណែកអភិវឌ្ឍធនាគារជាតិនៃកម្ពុជាឱ្យរីកចម្រើននិងសម្រេចបានសមិទ្ធផលជាទីមោទនៈ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៅទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលមួយថ្ងៃ សូមលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាខិតខំស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារដែលអនុវត្តកន្លងមកនិងលើកទិសដៅការងារឆមាសទី២ឆ្នាំ២០១៣ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួនឱ្យបានជោគជ័យនិងមានប្រសិទ្ធភាព ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនឹងនេះ សូមឱ្យអង្គសន្និបាតរបស់យើងមានដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**

ឲឲឲ✲៚៚៚

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១
## និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា
### នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣

**សូមគោរព :**

- **គណៈអធិបតី**
- **លោក Ye-Hong Ahn ជំនាញការធនាគារកណ្តាលកូរ៉េ ប្រចាំនៅធនាគារជាតិនៃកម្ពុជា**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា**

នៅពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជាយើង បានឈានដល់ទីបញ្ចប់ប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាលបំផុត ។ ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា សន្និបាតយើងថ្ងៃនេះបានប្រព្រឹត្តទៅដោយរលូន និងបានផ្តល់ខ្លឹមសារសំខាន់ៗចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់គ្នា ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកានៃអង្គសន្និបាតយើងពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗនៃការងាររបស់យើង អនុសាសន៍ណែនាំនិងទិសដៅការងារថ្មីៗយកទៅអនុវត្ត ដើម្បីបន្តរួមចំណែកអភិវឌ្ឍធនាគារជាតិនៃកម្ពុជានិងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនកាន់តែល្អប្រសើរថែមទៀត។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោក លោកស្រី ដែលបានផ្តល់បទអន្តរាគមន៍និងអនុសាសន៍ ជូនអង្គសន្និបាតយើង។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះសមាជិក-សមាជិកាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសន្និបាត និងខិតខំយកចិត្តទុកដាក់ស្តាប់ខ្លឹមសារសំខាន់ៗនៃទិសដៅការងារសម្រាប់ឆមាសទី២ និងមានវត្តមានក្នុងអង្គសន្និបាតនេះ តាំងពីដើមរហូតដល់ចប់ ។

**-គណៈអធិបតី**

**-លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

តាមរយៈស្មារតីអង្គសន្និបាតយើងក្នុងរយៈពេលមួយថ្ងៃនេះ ខ្ញុំបានកត់សម្គាល់ឃើញថា អង្គសន្និបាតរបស់យើងបានប្រព្រឹត្តទៅដោយជោគជ័យ ហើយបានផ្តោតលើចំណុចសំខាន់ៗដូចតទៅ៖

**I/- សមិទ្ធផលនិងទិសដៅការងាររបស់ធនាគារជាតិនៃកម្ពុជា ក្នុងឆមាសទី១ ឆ្នាំ២០១៣ :** លោកស្រី ងួន សុខា បានជម្រាបជូនអង្គសន្និបាតកាលពីព្រឹកមិញនេះ អំពីសមិទ្ធផលរីកចម្រើនរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាស្ថិរភាពថ្លៃ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កិច្ចសហប្រតិបត្តិការអន្តរជាតិ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ការងារប្រតិបត្តិការជាមួយសាខារាជធានី-ខេត្ត ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការងារសវនកម្មជាដើម ។ ការងារទាំងអស់នេះ ពិតជាបានរួមចំណែកក្នុងការពង្រឹងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា សុខភាព និងសុវត្ថិភាពប្រព័ន្ធធនាគារនៅកម្ពុជាទាំងមូល ការរក្សាស្ថិរភាពថ្លៃ និងជាពិសេស ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ។

**II/ - ចំពោះស្ថានភាពសេដ្ឋកិច្ចពិភពលោក តំបន់និងកម្ពុជា :** ដូចឯកឧត្តម ស៊ុំ សន្និសិទ្ធ បានជម្រាបជូនអង្គសន្និបាតរបស់យើងមុននេះបន្តិចអញ្ចឹងថា ក្នុងរយៈពេល ៦ឆ្នាំ ក្រោយពីវិបត្តិសកលសេដ្ឋកិច្ចពិភពលោកបាននិងកំពុងងើបឡើងយឺតៗជាវិជ្ជមាន ហើយបោះជំហានទៅមុខក្នុងភាពមិនទាន់ច្បាស់លាស់នៅឡើយ (one step in the dark) ដោយសារហានិភ័យនៃនិកម្មភាពខ្ពស់នៅប្រទេសអភិវឌ្ឍន៍មួយចំនួននិងបញ្ហាប្រឈមនៅតំបន់អឺរ៉ុប ។ បញ្ហាប្រឈមនេះមានដូចជា *(១)*-ប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុនៅមិនទាន់រឹងមាំនិងមានភាពផុយស្រួយនៅឡើយដោយសារគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួននៅតែមានអនុបាតបំណុលខ្ពស់ (Leverage) ក្នុងប្រព័ន្ធនិងគុណភាពទ្រព្យសកម្មមិនទាន់រឹងមាំដែលចាំបាច់ត្រូវពង្រឹង (De-leveraging) *(២)*-លំហូរមូលធនគំហុកខ្លាំងពីប្រទេសអភិវឌ្ឍន៍ទៅក្នុងប្រទេសកំពុងងើបឡើងនិងកំពុងអភិវឌ្ឍន៍ ដែលអាចធ្វើឱ្យមានកំណើនឥណទានខ្ពស់ ការកើនឡើងនៃថ្លៃអចលនទ្រព្យ សម្ពាធអតិផរណា និងការកើនឡើងនៃកំដៅសេដ្ឋកិច្ច និង *(៣)*-ការបន្តរក្សា និងទម្លាក់អត្រាការប្រាក់គោលឱ្យនៅទាបរបស់ប្រទេសអភិវឌ្ឍន៍យូរពេកជាហានិភ័យមួយដែលនាំឱ្យកំណើនសេដ្ឋកិច្ចធ្លាក់ចុះ (Downside Risks) ផងដែរ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើអាជ្ញាធរនៃប្រទេសក្នុងតំបន់ ជាពិសេស ធនាគារកណ្តាល បានប្រកាន់យកគោលការណ៍ថ្មីៗមួយចំនួន ដូចជា ៖

*(i)*-បន្តអនុវត្តកម្មវិធីកំណែទម្រង់ក្របខ័ណ្ឌបទប្បញ្ញត្តិ ដើម្បីពង្រឹងភាពរឹងមាំនិង អភិបាលកិច្ចល្អរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទាំងផ្នែកម៉ាក្រូប្រុងប្រយ័ត្ននិងផ្នែកមីក្រូប្រុងប្រយ័ត្នស្របតាមគោលការណ៍គ្រឹះស្តីពីការត្រួតពិនិត្យធនាគារថ្មីៗ (Basel III) របស់គណៈកម្មាធិការទីក្រុងបាសែលនិងវិធានការប្រុងប្រយ័ត្ននានា ដើម្បីត្រៀមទប់ទល់និងដោះស្រាយវិបត្តិហិរញ្ញវត្ថុ ។ ធនាគារកណ្តាលទាំងនោះក៏បានកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិរបស់ខ្លួន ដើម្បីពង្រឹងការគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានហានិភ័យជាប្រព័ន្ធ (SIFIs) ឱ្យកាន់តែស៊ីជម្រៅថែមទៀត ។

*(ii)*-ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ភាគច្រើន បានដាក់ចេញវិធានការគ្រប់គ្រងធនាគារធំៗក្នុងស្រុក ដែលមានហានិភ័យជាប្រព័ន្ធ (D-SIFIs) ស្របតាមស្ថានភាពជាក់ស្តែងនៃប្រទេសរបស់ខ្លួន ហើយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងស្រុកធំៗណាដែលមានហានិភ័យជាប្រព័ន្ធចាំបាច់ត្រូវគោរពតាមវិធានការប្រុងប្រយ័ត្នឱ្យបានហ្មត់ចត់ ដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមានជាយថាហេតុ។

*(iii)*- ធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ខ្លះខិតខំពង្រឹងអភិបាលកិច្ចល្អ និងយន្តការគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ខ្លួនថែមទៀត ខណៈដែលធនាគារកណ្តាលនៃប្រទេសឧស្សាហកម្ម និងប្រទេសអភិវឌ្ឍន៍មួយចំនួន កំពុងអនុវត្តគោលនយោបាយរូបិយវត្ថុវិសាមញ្ញ (Unconventional) ដូចជាការបន្តរក្សា និងទម្លាក់អត្រាការប្រាក់គោលរបស់ខ្លួនទាបយូរពេក ដើម្បីគាំទ្រស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

ដោយឡែក សេដ្ឋកិច្ចកម្ពុជាវិញមានមូលដ្ឋានកំណើនរឹងមាំដោយមិនទទួលរងនូវផលប៉ះពាល់ពីបញ្ហាប្រឈមនោះដោយផ្ទាល់ ។ នៅឆ្នាំ២០១៣នេះ បើតាមការព្យាកររបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងមានកំណើន ៧,៦% ប្រហាក់ប្រហែលនឹងឆ្នាំមុនដែរ ដោយសារភាពអំណោយផលពីកំណើននៃវិស័យកសិកម្ម ទេសចរណ៍ សំណង់ និងការនាំចេញជាដើម ។

ដើម្បីរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ខ្ញុំសូមលើកឡើងនូវមតិខ្លះៗ ដើម្បីឱ្យមន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត បានស្វែងយល់បន្ថែមអំពីអ្វី ដែលធនាគារជាតិនៃកម្ពុជាត្រូវធ្វើនៅពេលនេះ និងនៅពេលអនាគត ដូចខាងក្រោម ៖

១/-**ការពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ** : ដោយសារការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ទាំងផ្នែកបណ្តាញសេវា និងផលិតផលបច្ចុប្បន្ននេះ បានផ្តល់សញ្ញាណពីរ គឺទី១/-បានជួយរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ប៉ុន្តែចំណុចទី២/-បានបង្ហាញពីសញ្ញាណនៃការព្រួយបារម្ភសម្រាប់អាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករ ដើម្បីបង្កើនការយកចិត្តទុកដាក់គ្រប់គ្រងហានិភ័យទាំងឡាយ ដែលអាចកើតមានឡើងនៅពេលខាងមុខ ដោយសារការរីកចំរើននៃសេវានិងឧបករណ៍ហិរញ្ញវត្ថុ ។ ដូច្នេះ ការងារពង្រឹងសុវត្ថិភាពនិងស្ថិរភាពនៃប្រព័ន្ធធនាគារ គឺជាការងារអាទិភាពដែលយើងត្រូវអនុវត្តជាប់ជាប្រចាំទាំងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។ បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍប្រព័ន្ធ

ត្រួតពិនិត្យតាមដានលើឯកសារ (Off-Site Surveillance System) ដែលជាប្រព័ន្ធត្រួតពិនិត្យតាមដានតាមកម្មវិធីកុំព្យូទ័រដើម្បីបម្រើដល់ការត្រួតពិនិត្យផ្អែកលើហានិភ័យនិងផលិតរបាយការណ៍វិភាគផ្សេងៗ ជាលក្ខណៈស្វ័យប្រវត្តិនិងសុក្រិត។

ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ ត្រូវបន្តពង្រឹងនិងពង្រីកវិស័យនេះឱ្យរីកចម្រើនថែមទៀតឱ្យស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។ ដូច្នេះយើងត្រូវរៀបចំផែនការសកម្មភាព ដូចជា ១/-បង្កើនប្រសិទ្ធភាពនៃតួនាទីព័ត៌មានឥណទាន ២/-កែលម្អក្របខ័ណ្ឌច្បាប់និងប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣/-បង្កបរិយាកាសប្រកួតប្រជែងលើអត្រាការប្រាក់ សេវា និងផលិតផលហិរញ្ញវត្ថុ និង ៤/-ពង្រីកលទ្ធភាពប្រើប្រាស់ឥណទានចំពោះប្រជាជនដែលមានចំណូលទាបនៅតំបន់ជនបទបន្ថែមទៀត ។

**២/- ចំពោះការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** : គឺជាការងារស្នូលរបស់យើង ជាពិសេសជាការងារពង្រឹងសុវត្ថិភាពនិងមានសារៈសំខាន់ណាស់សម្រាប់វាយតម្លៃពីភាពរឹងមាំ សុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ស្របតាមគោលការណ៍អភិបាលកិច្ច។ តាមរយៈរបាយការណ៍របស់លោកអគ្គពិនិត្យផ្ញើជូនមកខ្ញុំជាប់ជាប្រចាំ ខ្ញុំបានពិនិត្យឃើញថា មន្ត្រីយើងបានបំពេញការងារនេះបានល្អប្រសើរ ។

ដើម្បីបន្តដំណើរការការងារនេះឱ្យប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាពថែមទៀត ខ្ញុំសូមស្នើសុំឱ្យបន្តចុះតាមដានការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើងនិងរៀបចំយន្តការវាយតម្លៃហានិភ័យប្រតិបត្តិការតាមផ្នែកនិងពង្រឹងការងារអធិការកិច្ចទាំងនៅទីស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្តបន្តទៀត ។ សូមឱ្យមន្ត្រីបុគ្គលិកនៅតាមនាយកដ្ឋានជំនាញ និងអង្គភាពក្រោមឱវាទផ្តល់កិច្ចសហការបន្ថែមទៀត ។

**៣/- ការងារគ្រប់គ្រងធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា:** ឯកឧត្តម ស៊ុំ សន្និសិទ្ធបានអធិប្បាយនិងពន្យល់ច្បាស់លាស់ហើយ។ ខ្ញុំសូមឯកភាពតាមមតិទាំងនេះ។ ខ្ញុំស្នើសុំឱ្យមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់អនុវត្តតាមស្មារតីណែនាំខាងលើនេះ ដើម្បីរួមចំណែកពង្រឹងប្រសិទ្ធភាពការងារធនាគារជាតិនៃកម្ពុជាឱ្យកាន់តែប្រសើរថែមទៀត ។ ធនធានមនុស្សគឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ យើងបានបណ្តុះបណ្តាលកម្លាំងបន្តវេនលើផ្នែកជំនាញជាប់ជាប្រចាំ ដើម្បីបន្តនិរន្តរភាព និងស្ថិរភាពការងាររបស់យើងនាពេលអនាគតស្របពេលដែលថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិករបស់យើងមួយចំនួនកំពុងចូលនិវត្តន៍ជាបណ្តើរៗ ។

បច្ចុប្បន្ន យើងជំរុញឱ្យមានការបណ្តុះបណ្តាលគ្រប់រូបភាពទាំងក្នុងនិងក្រៅប្រទេស ។ ក្នុងប្រទេស យើងបានរៀបចំវគ្គផ្លាស់ប្តូរយោបល់គ្នា និងវគ្គបណ្តុះបណ្តាលផ្សេងៗ ចំណែកក្រៅប្រទេស យើងមានដៃគូអភិវឌ្ឍក្នុងតំបន់និងអន្តរជាតិដូចជា IMF, ADB, WB, មជ្ឈមណ្ឌល

SEACEN, ASEAN, ASEAN+3 និងការបណ្តុះបណ្តាលជាលក្ខណៈទ្វេភាគីជាមួយធនាគារកណ្តាល នៅតំបន់អឺរ៉ុបមាន ធនាគារកណ្តាលបារាំង អាល្លឺម៉ង់ និងលុចហ្សំបួរ និងនៅតំបន់អាស៊ីមាន ធនាគារកណ្តាល ថៃ ម៉ាឡេស៊ី កូរ៉េ វៀតណាម ឡាវ និងម៉ុងហ្គោលី ជាដើម ។

នៅឆមាសទី២ ឆ្នាំ២០១៣នេះ ខណៈពេលដែលយើងខិតខំបណ្តុះបណ្តាលជំនាញឯកទេស ដូចជាជំនាញគណនេយ្យ ការត្រួតពិនិត្យធនាគារ សវនកម្ម និងប្រព័ន្ធទូទាត់ ធនាគារជាតិនៃកម្ពុជា នឹងរៀបចំបើកវគ្គបណ្តុះបណ្តាលធនាគារកណ្តាល (Central Banking Courses) កម្រិតមូលដ្ឋាន និងមធ្យមស្តីពីភាពជាអ្នកដឹកនាំ និងវគ្គបាគងស្តីពី ការត្រួតពិនិត្យធនាគារផងដែរ ។ វគ្គនេះនឹងត្រូវរៀបចំជារៀងរាល់ឆ្នាំ ក្រោមរូបភាពជា In-house Training ដើម្បីចែករំលែកនូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍ការងារជាក់ស្តែងរបស់ថ្នាក់ដឹកនាំជូនចំពោះមន្ត្រីបុគ្គលិកដែលជាអ្នកបន្តវេនជំនាន់ក្រោយ ។ វគ្គនេះមានសារៈសំខាន់ណាស់សម្រាប់ធនាគារជាតិនៃកម្ពុជាយើងក្នុងការបណ្តុះបណ្តាលមន្ត្រីយើងឱ្យមានឆន្ទៈនិងមនសិការស្រឡាញ់និងការពារស្ថាប័ន មានភាពស្មោះត្រង់និងបំពេញការងារស្នូលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងការប្តេជ្ញាចិត្តរួមសាមគ្គី ដើម្បីបន្តអភិវឌ្ឍធនាគារជាតិនៃកម្ពុជាឲ្យកាន់តែរីកចំរើនតរៀងទៅ ។

ជាមួយគ្នានេះ ខ្ញុំសូមជម្រាបថា ធនាគារជាតិនៃកម្ពុជានឹងរៀបចំប្រឡងឆ្លងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣ ខាងមុខនេះផងដែរ ។ ចំណែកឯការអនុវត្តតាមស្មារតីនៃប្រកាសលក្ខន្តិកៈដោយឡែករបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាឱ្យមានប្រសិទ្ធភាព សូមនាយកដ្ឋានបុគ្គលិកខិតខំផ្សព្វផ្សាយដល់មន្ត្រីបុគ្គលិកយើង ទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្តតាមស្មារតីណែនាំរបស់ឯកឧត្តមអគ្គលេខាធិការ ។

**៤)- ការអភិវឌ្ឍប្រព័ន្ធទូទាត់** : នេះគឺជាតួនាទីសំខាន់របស់ធនាគារជាតិនៃកម្ពុជា ។ បច្ចុប្បន្នប្រតិបត្តិការទូទាត់សងប្រាក់ ដូចជា មូលប្បទានបត្រ ការបញ្ជាទូទាត់ Credit Card, Debit Card, ATM, Easy Cash និងការទូទាត់តាមបណ្តាញទូរសព្ទចល័តនិងសេវា Wing ជាដើម កំពុងមានការរីកចម្រើនយ៉ាងខ្លាំងនៅកម្ពុជា ទាំងផ្នែកបណ្តាញសេវានិងផលិតផលហិរញ្ញវត្ថុ។ ដើម្បីបំពេញតម្រូវការនេះ កាលពីចុងឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យដំណើរការជាផ្លូវការនូវប្រព័ន្ធ-ជាតិផាត់ទាត់ ដែលយើងអាចធ្វើការផាត់ទាត់ទាំងមូលប្បទានបត្រ និងឧបករណ៍ទូទាត់សងប្រាក់តាមអេឡិចត្រូនិក ។

**៥/- ការងារអគ្គលេខាធិការនិងក្រុមប្រឹក្សាវិន័យ**: ឯកឧត្តម ថា យ៉ាវ បានជម្រាបជូនអង្គសន្និបាតទាក់ទងនឹងការពង្រឹងវិន័យការងារ ខ្ញុំសូមឯកភាពតាម ឯកឧត្តម ថា យ៉ាវ ដែលបានបញ្ជាក់ថា ការគោរពវិន័យការងារនាំមកនូវសេចក្តីថ្លៃថ្នូរ និងកិត្តិយស បុណ្យសក្តិ និងសក្ការៈ និងបង្កើតបរិស្ថានការងារល្អមានការគោរពគ្នាទៅវិញទៅមក ហើយប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ។

ដើម្បីអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ខ្ញុំស្នើសុំឱ្យអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាទាំងអស់ ត្រូវគោរពបទបញ្ជាផ្ទៃក្នុង និងពង្រឹងវិន័យការងាររបស់ធនាគារជាតិនៃកម្ពុជា ដោយខិតខំព្យាយាមលុបបំបាត់នូវចំណុចអសកម្មទាំងឡាយដែលឯកឧត្តមប្រធានក្រុមប្រឹក្សាវិន័យបានលើកឡើងនិងបានដាក់ចេញវិធានការថ្មីៗនេះ ។ ចំពោះសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តវិញ ត្រូវពង្រឹងវិន័យការងារ និងត្រូវចាត់តាំងឱ្យមានអ្នកប្រចាំការនៅកន្លែងការងារនៅរៀងរាល់ថ្ងៃចុងសប្តាហ៍ និងថ្ងៃបុណ្យ ដើម្បីរក្សាការពារនូវសុវត្ថិភាពទ្រព្យសម្បត្តិយើងកុំឱ្យបាត់បង់ ឬ បង្ការគ្រោះមានហេតុការណ៍ណាមួយកើតឡើងដោយចៃដន្យ ដូចជាទឹកជំនន់ និងគ្រោះធម្មជាតិផ្សេងទៀត ទើបយើងអាចសហការដោះស្រាយបានទាន់ពេលវេលា ។ ចំពោះការងារគ្រប់គ្រងបេឡាប្រតិបត្តិការ ការផ្គត់ផ្គង់ធនបត្រ ការគ្រប់គ្រង ការថែរក្សាការពារឃ្លាំងទ្រព្យសម្បត្តិ និងការដឹកជញ្ជូនធនបត្រ មានការរីកចម្រើនយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្នែកបរិមាណ និងគុណភាព ជាពិសេស បន្ទាប់ពីយើងបានកែលម្អសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តឡើងវិញ ។ ការងារអគ្គបេឡា គឺជាការងារបច្ចេកទេសដែលទាមទារទាំងផ្នែកជំនាញស្មារតីទទួលខុសត្រូវភាពស្មោះត្រង់ និងការតស៊ូ អត់ធ្មត់ចំពោះការងារ ។ ដូច្នេះ ដើម្បី បង្កើនប្រសិទ្ធភាពការងារ តម្រូវឱ្យមន្ត្រីទាំងអស់បន្តប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ សីលធម៌ វិន័យការងារ និងគោរពតាមការចាត់តាំងបន្ថែមទៀត ។ ការថែរក្សាសុវត្ថិភាពឃ្លាំងទ្រព្យសម្បត្តិជាតិ តម្រូវឱ្យមន្ត្រីមានវិន័យការងារ ភាពស្មោះត្រង់ និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការទុកដាក់ និងគ្រប់គ្រងទ្រព្យសម្បត្តិតាមលក្ខណៈបច្ចេកទេស ព្រមទាំងត្រូវបង្កើនការប្រុងប្រយ័ត្នថែមទៀត ដើម្បីការពារទឹកជំនន់ ។

**៦/-ការពង្រឹងប្រតិបត្តិការជាមួយសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត:** គឺជាយន្តការពង្រឹងប្រតិបត្តិការរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជាតាមរយៈការសម្របសម្រួល និងដាក់ឱ្យចរាចរប្រាក់រៀល ការប្រមូលនិងការទទួលដូរក្រដាសប្រាក់ចាស់សឹករេចរឹល ហើយដាក់ជំនួសក្រដាសប្រាក់ថ្មីវិញ ។ ការងារនេះ គឺជាការងារអាទិភាពរបស់យើង ហើយក៏ជាយន្តការជំរុញការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលផងដែរ ។ ដូច្នេះ ខ្ញុំសូមស្នើសុំឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តត្រូវពង្រឹងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងដែនដីរដ្ឋបាល ដើម្បីសម្រួលដល់ការដាក់ឱ្យចរាចរប្រាក់រៀលឱ្យប្រព្រឹត្តទៅដោយរលូន និងកាន់តែទូលំទូលាយថែមទៀត ។

**-គណៈអធិបតី**

**-លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា**

ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើនេះ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជាដែលត្រូវអនុវត្តចំពោះមុខ ទាំងរយៈពេលមធ្យមនិងវែងនៅពេលអនាគត ដើម្បីពង្រឹងប្រព័ន្ធធនាគារ

ទាំងមូលឱ្យប្រព្រឹត្តទៅដោយរលូននិងមានសុវត្ថិភាព ។ ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ នឹងបន្តការខិតខំប្រឹងប្រែងអនុវត្តទិសដៅភារកិច្ចទាំងឡាយឱ្យសម្រេចបានជោគជ័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យមានការអភិវឌ្ឍរីកចម្រើនប្រកបដោយចីរភាព។

**មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើនូវមតិមួយចំនួនដូចខាងក្រោម ៖**

១/-ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅបន្តផ្សព្វផ្សាយនៅតាមនាយកដ្ឋាន និងអង្គភាពរៀងៗខ្លួននូវខ្លឹមសារ និងអនុសាសន៍ល្អៗ ដើម្បីអនុវត្តចំពោះការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

២/-បន្តអនុវត្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០ របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យប្រព្រឹត្តទៅដោយរលូនមានប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ធនាគារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិ និងអន្តរជាតិ។ ដើម្បីសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាបន្តស្មារតីរួមសាមគ្គី សហការគ្នាជាប្រពៃណី និងទទួលខុសត្រូវខ្ពស់ចំពោះការងារ ដើម្បីរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗថែមទៀត និងកាន់តែមានប្រសិទ្ធភាពស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**

៙៙៙✲៚៚៚

*បកប្រែក្រៅផ្លូវការ*

# សុន្ទរកថាគន្លឹះ
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងសន្និសីទ លើកទី៩ ស្តីពី ការគ្រប់គ្រងបំណុល
# នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣

**សូមគោរព :**

**គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាអនេកដោយបានចូលរួមថ្លែងសុន្ទរកថាគន្លឹះក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ (UNCTAD) លើកទី៩ អំពីការគ្រប់គ្រងបំណុលនេះ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ UNCTAD ដែលបានរៀបចំកម្មវិធីនេះឡើង ដើម្បីពិភាក្សាអំពីបញ្ហាទាក់ទងនឹងបំណុលសាធារណៈ ស្របពេលដែលប្រទេសភាគច្រើនកំពុងជួបប្រទះ ។

ខ្ញុំជឿជាក់ថា សន្និសីទរបស់យើងថ្ងៃនេះនឹងផ្តល់ឱកាសសម្រាប់អ្នករៀបចំគោលនយោបាយ និងអ្នកគ្រប់គ្រងបំណុលមកពីប្រទេសក្នុងតំបន់ជុំវិញពិភពលោកជួបជុំគ្នា ដើម្បីពិភាក្សាអំពីបញ្ហាសំខាន់ៗ ដែលយើងកំពុងប្រឈមក្នុងស្ថានភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ន ។ ក្នុងសន្និសីទនេះ ខ្ញុំសង្កេតឃើញមានតំណាងក្រសួង ស្ថាប័ន និងអង្គភាពមកពីគ្រប់តំបន់ក្នុងពិភពលោក ដើម្បីពិភាក្សានិងផ្លាស់ប្តូរព័ត៌មានគ្នា ។ ខ្ញុំរង់ចាំពិភាក្សាអំពីបញ្ហាដែលពាក់ព័ន្ធនេះ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមលើកឡើងនូវមតិខ្លះៗទាក់ទងនឹងបញ្ហាប្រឈមមួយចំនួន ដែលប្រទេសកំពុងអភិវឌ្ឍន៍កំពុងជួបប្រទះក្នុងការគ្រប់គ្រង និងរក្សាកម្រិតបំណុលរបស់ខ្លួនប្រកបដោយចីរភាពក្នុងបរិបទសេដ្ឋកិច្ចពិភពលោកពេលបច្ចុប្បន្ន និងផ្តោតជាសំខាន់ទៅលើតម្រូវការថ្នាក់ជាតិ និងវិធានការរបស់សហគមន៍អន្តរជាតិ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិបំណុលសាធារណៈបច្ចុប្បន្ន និងទៅអនាគត ព្រមទាំងពិចារណាលើឧបករណ៍និងយន្តការដោះស្រាយវិបត្តិបំណុលដែលអាចកើតឡើងនាពេលអនាគតផងដែរ ។

**១/- ចីរភាពបំណុលក្នុងបរិបទសេដ្ឋកិច្ចសកលបច្ចុប្បន្ន :**

ចាប់តាំងពីការផ្ទុះឡើងនៃវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ២០០៨មក បើយើងរៀបរាប់វាមិនអស់សេចក្តីទេ ព្រោះសេដ្ឋកិច្ចពិភពលោកបានទទួលរងនូវការប្រែប្រួលខ្លាំងគួរឱ្យកត់សម្គាល់។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចកន្លងមកបណ្តាលមកពីហានិភ័យជាច្រើន ក្នុងនោះ មានភាពមិនប្រាកដប្រជាជាច្រើនដែលបានលេចឡើងហានិភ័យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច និងចីរភាពបំណុលរបស់ប្រទេស

អភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ជាដើម ។ កន្លងមក យើងបានសង្កេតឃើញថា ការងើបឡើងវិញយឺតៗនៃសេដ្ឋកិច្ចពិភពលោក បានក្លាយជាបញ្ហាប្រឈមសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសក្នុងការសម្រេចគោលដៅអភិវឌ្ឍរបស់ខ្លួន ។

បច្ចុប្បន្ន យើងកំពុងរស់នៅក្នុងបរិយាកាសសេដ្ឋកិច្ចពិភពលោកថ្មីមួយទៀតដែលមានកំណើនយឺតនិងហានិភ័យអត្រាការប្រាក់កើនឡើង ។ ប្រភពហិរញ្ញប្បទានក្នុងអត្រាការប្រាក់ទាបដែលប្រទេស ជាច្រើនអាចស្វែងរកបានកន្លងមកអាចនឹងជិតដល់ទីបញ្ចប់ហើយ ដោយអត្រាការប្រាក់លើសញ្ញាប័ណ្ណរយៈពេលវែងបានចាប់ផ្តើមកើនឡើងជាបន្តបន្ទាប់ ។ ការវិវត្តនេះ បានបង្កើតជាបញ្ហាប្រឈមសំខាន់ៗសម្រាប់ប្រទេសនានាក្នុងការគ្រប់គ្រង និងរក្សាកម្រិតបំណុលរបស់ខ្លួនប្រកបដោយចីរភាព ជាពិសេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលអាចស្វែងរកប្រភពហិរញ្ញប្បទានបានតិចតួចជាងប្រទេសអភិវឌ្ឍន៍ ។ មិនត្រឹមតែប៉ុណ្ណោះ ការអនុវត្តគោលនយោបាយសារពើពន្ធវិត្តារកម្មយ៉ាងខ្លាំងក្លាកន្លងមករបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីឆ្លើយតបនឹងវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល ក៏បានធ្វើឱ្យលទ្ធភាពគោលនយោបាយរបស់ខ្លួនថយចុះ ដែលបានបង្កជាហានិភ័យនិងប៉ះពាល់ដល់ចីរភាពបំណុលផងដែរ ។

ស្ថានភាពនេះកាន់តែមានភាពស្មុគស្មាញដោយសារភាពមិនប្រាកដប្រជា និងកំណើនសេដ្ឋកិច្ចទាបរបស់បណ្តាប្រទេសអភិវឌ្ឍន៍ ហើយគួបផ្សំនឹងកំណើនសន្ទនីយភាពពិភពលោកដែលបានច្រាលចេញពីប្រទេសអភិវឌ្ឍន៍ សំដៅស្វែងរកផលចំណេញខ្ពស់ ក៏បានប៉ះពាល់ការគ្រប់គ្រងបំណុលរបស់ប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ ។ កន្លងមក ការកើនឡើងយ៉ាងខ្លាំងនៃកម្រិតសន្ទនីយភាពសកលបានធ្វើឱ្យគម្លាតអត្រាការប្រាក់ថយចុះ ហើយប្រទេសកំពុងអភិវឌ្ឍន៍មានភាពងាយស្រួលក្នុងការទទួលបានប្រភពហិរញ្ញប្បទានដែលមានអត្រាការប្រាក់ទាប ។ ប៉ុន្តែការណ៍នេះបានជំរុញ និងលើកទឹកចិត្តដល់ប្រទេសកំពុងអភិវឌ្ឍន៍ឱ្យងាកទៅរកយន្តការខ្ចីបំណុលពីទីផ្សារអន្តរជាតិកាន់តែច្រើនឡើងទោះបីជាការខ្ចីនេះមានហានិភ័យខ្ពស់ក៏ដោយ ។ ភាពមិនប្រាកដប្រជាជុំវិញជំហរគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ ឧទាហរណ៍ដូចជា ការកំណត់ពេលវេលា និងជំហានសម្រាប់ចាកចេញពីគោលនយោបាយវិត្តារកម្ម គួបផ្សំនឹងបំណុលសាធារណៈមានកម្រិតខ្ពស់អាចជំរុញឱ្យទីផ្សារហិរញ្ញវត្ថុមានការប្រែប្រួលកាន់តែខ្លាំង និងប៉ះពាល់ដល់ការគ្រប់គ្រងបំណុលសាធារណៈរបស់ប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ ។ ចំណុចនេះក៏បានបង្ហាញពីអត្ថប្រយោជន៍ខ្ពស់ក្នុងការរៀបចំយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យទាំងនេះ ។

**២/- ហានិភ័យចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានចំណូលទាប :**

វិបត្តិកន្លងមកនេះ បានបង្កើនបន្ទុកចំណាយផ្នែកសេដ្ឋកិច្ចជាច្រើនសម្រាប់ប្រទេសនានា

ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ តួយ៉ាងមុនពេលមានវិបត្តិទុនបម្រុងអន្តរជាតិរបស់ប្រទេសកំពុងអភិវឌ្ឍន៍បានកើនឡើងជាលំដាប់ ដែលផ្តល់លទ្ធភាពដល់ប្រទេសទាំងនោះ អាចទ្រទ្រង់នឹងលំហូរចេញដ៏ច្រើននៃមូលធន និងអាចឆ្លើយតបបានយ៉ាងប្រសើរទៅនឹងវិបត្តិពិភពលោកកន្លងមក ។ ក្រុមប្រទេសកំពុងអភិវឌ្ឍន៍មានស្ថានភាពរឹងមាំក្នុងការប្រឈមនឹងផលប៉ះពាល់អវិជ្ជមានពីវិបត្តិ ដោយសារតែអនុវត្តរាគមន៍គោលនយោបាយយ៉ាងសកម្មនិងកំណើនសេដ្ឋកិច្ចរឹងមាំមុនពេលមានវិបត្តិ ។ បើយើងក្រឡេកមើលទៅចរន្តឆ្លងនៃវិបត្តិហិរញ្ញវត្ថុសកលទៅប្រទេសកំពុងអភិវឌ្ឍន៍ គឺកើតឡើងតាមរយៈវិស័យពិត ដូចជា ការធ្លាក់ចុះនៃពាណិជ្ជកម្ម ការវិនិយោគ ការផ្ញើប្រាក់ និងការធ្លាក់ចុះនៃជំនួយអភិវឌ្ឍន៍ផ្សេងៗ ។ ភាពទន់ខ្សោយនៃសូចនាករសេដ្ឋកិច្ចទាំងនេះបានបង្កើតជាបញ្ហាប្រឈមក្នុងការគ្រប់គ្រងបំណុលកាន់តែខ្លាំង ។

ដោយឡែក ប្រទេសដែលមានចំណូលទាបមានឱកាសនិងធនធានហិរញ្ញប្បទានតិចតួច បើធៀបនឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ។ ជាទូទៅ ទីផ្សារបំណុលក្នុងស្រុកមិនទាន់មានការអភិវឌ្ឍគ្រប់គ្រាន់ ជាពិសេស ទីផ្សារបំណុលរយៈពេលវែង ហើយធនធានដែលប្រមូលបានមានកម្រិតតិចតួច ដោយសារទំហំនៃការសន្សំនៅមានកម្រិតនៅឡើយ។ ជាមួយគ្នានេះដែរ ដើម្បីអភិវឌ្ឍទីផ្សារបំណុលក្នុងស្រុកនេះក៏ទាមទារចំណាយច្រើនផងដែរ ទាំងធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ។ សំខាន់ជាងនេះទៅទៀត កម្ចីក្នុងស្រុកមិនអាចជំនួសហិរញ្ញប្បទានក្រៅប្រទេសបានពេញលេញ និងភ្លាមៗនោះទេ ដោយទាមទារឱ្យប្រទេសដែលមានចំណូលទាបទាំងនេះ ត្រូវបង្កើនទុនបម្រុងអន្តរជាតិដើម្បីយកទៅទិញមូលធនពីបរទេស មកបំពេញតម្រូវការគម្រោងវិនិយោគរបស់ខ្លួនបាន ។ ប៉ុន្តែបញ្ហាអតុល្យភាពគណីចរន្តបានបង្ហាញថា មូលធនពីបរទេសនឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍរបស់ប្រទេសទាំងនោះ ។

ការថយចុះនៃលទ្ធភាពក្នុងការធ្វើនយោបាយសារពើពន្ធវិត្តារកម្មរបស់ប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើឱ្យប្រទេសទាំងនេះងាយនឹងរងគ្រោះដោយសារឥទ្ធិពលពីខាងក្រៅ និងហានិភ័យដែលកើតឡើងដោយការបង្គរបំណុលថ្មីៗបន្ថែម ជាពិសេសសម្រាប់ប្រទេសមានចំណូលទាប ដែលក្នុងនោះរួមទាំងកម្ពុជាផងដែរ ។

សម្រាប់ប្រទេសកម្ពុជាក៏ដូចជាប្រទេសមានចំណូលទាបដ៏ទៃទៀតដែរ ទោះបីជាបន្ទុកបំណុលខាងក្រៅស្ថិតក្នុងកម្រិតទាបនៅឡើយ ក៏ប្រទេសកម្ពុជានៅតែងាយទទួលរងគ្រោះដោយឥទ្ធិពលពីកត្តាខាងក្រៅ ។ ការងើបឡើងយឺតៗនៃសេដ្ឋកិច្ចសកល បានបង្ហាញពីភាពចាំបាច់របស់រដ្ឋាភិបាលក្នុងការរក្សាកម្រិតបំណុលប្រកបដោយចីរភាព ។

**៣/- ចក្ខុវិស័យ៖ ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក យុទ្ធសាស្ត្រគ្រប់គ្រងបំណុលប្រកបដោយប្រសិទ្ធភាព ការបាត់បង់បណ្តាញទំនាក់ទំនង :**

បើទោះជាសេដ្ឋកិច្ចសកលបន្តងើបឡើងចេញពីវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ក៏ដោយក៏មានការងារជាច្រើននៅតែបន្តជាអាទិភាពនិងជាបញ្ហាប្រឈម ដែលអ្នករៀបចំគោលនយោបាយ និងអ្នកគ្រប់គ្រងបំណុលនៅបណ្តាប្រទេសនានាត្រូវជំនះ ដើម្បីសម្រេចបាននូវការវិលត្រឡប់ទៅរកភាពប្រក្រតីវិញនៃកម្រិតបំណុល ។

ការងើបចេញពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលនៅតែមានសន្ទុះយឺត ដោយសារតែផលលំបាកក្នុងការសម្រួលតុល្យភាពថវិកា (រដ្ឋ សហគ្រាស និងគ្រួសារ) ឡើងវិញក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួន ។ លើសពីនេះ កំណើនសេដ្ឋកិច្ចសកលបាន និងកំពុងធ្លាក់ចុះជាថ្មីម្តងទៀត ហើយភាពមិនប្រាកដប្រជា និងហានិភ័យមួយចំនួននៅតែជាការគំរាមកំហែង ដែលអាចធ្វើឱ្យសេដ្ឋកិច្ចធ្លាក់ចុះ ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចនេះ ហាក់ដូចជាបានធ្វើឲ្យបញ្ហានានាជុំវិញកម្រិតបំណុលសាធារណៈកាន់តែមានសភាពធ្ងន់ធ្ងរ និងបានគំរាមកំហែងដល់លទ្ធភាពទទួលបានជំនួយអភិវឌ្ឍន៍នានាផងដែរ ។ ទាំងនេះបានជះឥទ្ធិពលអវិជ្ជមានដល់ចីរភាពបំណុលសាធារណៈក្នុងប្រទេសទាំងនោះ ។ ជាក់ស្តែងកំណើនសេដ្ឋកិច្ចនិងតម្រូវការសកលនៅមានកម្រិតទាប បានជះឥទ្ធិពលអវិជ្ជមានដល់ចំណូលនាំចេញរបស់ប្រទេសទាំងនោះ ហើយភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលបានធ្វើឲ្យការវិនិយោគធ្លាក់ចុះ និងដាក់បន្ទុកទៅលើកញ្ចប់ថវិកាជំនួយ ដែលបង្កើតជាការព្រួយបារម្ភអំពីជំនួយអភិវឌ្ឍន៍សម្រាប់ឆ្នាំខាងមុខ ។

ជាទស្សនៈវិស័យទៅអនាគត យើងត្រូវទទួលស្គាល់ថា ការរក្សាបាននូវចីរភាពបំណុលសាធារណៈអាស្រ័យទៅនឹងកត្តាជាច្រើន រួមមានកំណើនសេដ្ឋកិច្ចនាពេលអនាគត លក្ខខណ្ឌឥណទានស្ថានភាពពាណិជ្ជកម្ម ហានិភ័យអត្រាប្តូរប្រាក់ ហានិភ័យអត្រាការប្រាក់ ព្រមទាំងកត្តាមួយចំនួនផ្សេងទៀតផងដែរ។ អ្នករៀបចំគោលនយោបាយ ក៏ដូចជាអ្នកគ្រប់គ្រងបំណុលនានា ត្រូវលើកកម្ពស់ការយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រងហានិភ័យ និងឆ្លើយតបនឹងបញ្ហានានាក្នុងស្ថានភាពសេដ្ឋកិច្ចមិនប្រាកដប្រជានេះ ហើយនេះជាការងារដ៏ចាំបាច់មួយដែលទាមទារការចូលរួម និងចាត់វិធានការទាំងកម្រិតថ្នាក់ជាតិនិងអន្តរជាតិ ។

ការកំណត់បាន និងទប់ស្កាត់បញ្ហាមុនពេលកើតឡើង គឺជាកូនសោរគន្លឹះក្នុងការរក្សាបាននូវចីរភាពបំណុលសាធារណៈ ។ ក្នុងកម្រិតថ្នាក់ជាតិ ខ្ញុំសូមគូសបញ្ជាក់អំពីចំណុចសំខាន់ៗមួយចំនួនសម្រាប់ជាការពិចារណាក្នុងការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈនេះ ក្នុងនោះរួមមាន ១/-ការប្រើប្រាស់ឥណទានឱ្យបានត្រឹមត្រូវ ២/-ការអនុវត្តកម្មវិធីគ្រប់គ្រងបំណុលដោយប្រុងប្រយ័ត្ន និងសមស្រប ៣/-ការជ្រើសរើសប្រភពហិរញ្ញប្បទានដែលល្អ ៤/-ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រង

បំណុលប្រកបដោយប្រសិទ្ធភាព និង ៥/-ការអនុវត្តយន្តការខ្ចី និងផ្តល់កម្ចីប្រកបដោយការទទួលខុសត្រូវខ្ពស់ ។ ក្រៅពីការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលប្រកបដោយប្រសិទ្ធភាព យើងត្រូវយកចិត្តទុកដាក់ផងដែរចំពោះការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ។

ក្រៅពីយុទ្ធសាស្ត្រថ្នាក់ជាតិទាំងនេះ សហគមន៍អន្តរជាតិក៏មានតួនាទីសំខាន់ក្នុងការជំរុញកិច្ចខំប្រឹងប្រែងដោះស្រាយបញ្ហាទាំងនេះ នៅពេលមានបញ្ហាកើតឡើងផងដែរ។ ក្នុងស្ថានភាពបច្ចុប្បន្ន ស្ថាបត្យកម្មហិរញ្ញវត្ថុសកលនៅមិនទាន់មានការអភិវឌ្ឍ និងតភ្ជាប់គ្នាជាបណ្តាញគ្រប់គ្រាន់នៅឡើយទេ ហើយកង្វះខាតនេះក៏បានធ្វើឱ្យយន្តការដោះស្រាយបំណុលសាធារណៈនៅមានកម្រិត។ ជាលទ្ធផល ការដោះស្រាយបំណុលនៅតែមានលក្ខណៈយឺត និងមិនគ្រប់គ្រាន់។ ជាក់ស្តែង ការដោះស្រាយវិបត្តិបំណុលនៃប្រទេសក្រិច គឺជាភស្តុតាងមួយយ៉ាងច្បាស់បញ្ជាក់ថា សហគមន៍អន្តរជាតិនៅមិនទាន់មានយន្តការគ្រប់គ្រង និងដោះស្រាយវិបត្តិបំណុលសាធារណៈឱ្យបានទាន់ពេលវេលានៅឡើយទេ ។

**៤/- ការងាររបស់ UNCTAD :**

ការងារវិភាគរបស់ UNCTAD ទាក់ទងនឹងបញ្ហាបំណុល ជាពិសេសរបាយការណ៍ ស្តីពីបញ្ហាបំណុលរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបានរៀបចំសម្រាប់មហាសន្និបាតអង្គការសហប្រជាជាតិ បានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ជាអន្តរជាតិ អំពីបញ្ហាបំណុលនេះ ។

ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយផងដែរ ដែលកាលពីដើមឆ្នាំនេះ UNCTAD បានដឹកនាំបង្កើតក្រុមការងារមួយដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីពិនិត្យ និងសិក្សាលើយន្តការដោះស្រាយបំណុលសាធារណៈ។ ដំណើរការរបស់ក្រុមការងារមានតម្លាភាព និងជាសញ្ញាណវិជ្ជមានក្នុងការបង្កើតចេញនូវក្របខណ្ឌដោះស្រាយមួយដ៏ល្អដែលអាចឱ្យម្ចាស់បំណុល និងកូនបំណុលទទួលយកបាន។ បទពិសោធន៍ពីវិបត្តិហិរញ្ញវត្ថុសកល និងព្រឹត្តិការណ៍មួយចំនួននាពេលថ្មីៗនេះបានធ្វើឱ្យមានការទទួលស្គាល់កាន់តែច្រើនឡើងថា កង្វះខាតនៃយន្តការដោះស្រាយបញ្ហាបំណុលនេះ គឺជាចំណុចខ្វះខាតមួយក្នុងស្ថាបត្យកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលធ្វើឱ្យដំណើរការកែសម្រួលរចនាសម្ព័ន្ធបំណុលកន្លងមកមានលក្ខណៈយឺតយ៉ាវនិងមិនគ្រប់គ្រាន់។ ដោយឡែក ការបំពេញចំណុចខ្វះខាតនេះក៏ទាមទារការចូលរួមនិងគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធផងដែរ ។

ក្រៅពីនេះ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលរបស់កម្មវិធីប្រព័ន្ធវិភាគហិរញ្ញវត្ថុនិងគ្រប់គ្រងបំណុល (DMFAS) របស់ UNCTAD ដែលបានផ្តល់ជាជំនួយក្នុងសកម្មភាពគ្រប់គ្រងបំណុលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិជាច្រើន រួមមានការជួយគ្រប់គ្រងប្រព័ន្ធទិន្នន័យ

បំណុល ការធ្វើសពលកម្មទិន្នន័យបំណុល ប្រតិបត្តិការបំណុល ប្រព័ន្ធរាយការណ៍បំណុលខាងក្នុង និងខាងក្រៅ ស្ថិតិបំណុល និងការវិភាគបំណុលថ្នាក់មូលដ្ឋាន ការអភិវឌ្ឍប្រព័ន្ធភ្ជាប់ទំនាក់ទំនង រវាងការគ្រប់គ្រងបំណុលនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្សេងទៀត ។ ជំនួយទាំងនេះ គឺបាន បំពេញបន្ថែមឱ្យសកម្មភាពគ្រប់គ្រងបំណុលផ្សេងទៀត ដូចជាការវិភាគចីរភាពបំណុល ដែលត្រូវបាន ជួយវិភាគដោយមូលនិធិរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោក។ ជាការពិតកម្មវិធីនេះ សបញ្ជាក់ ពីកិច្ចសហប្រតិបត្តិការជាប្រព័ន្ធរវាង UNCTAD និងអង្គការជាដៃគូនានាក្នុងការផ្តល់ជំនួយបច្ចេកទេស ក្នុងការគ្រប់គ្រងបំណុល ។

ជាកិច្ចបញ្ចប់ ខ្ញុំសូមជូនពរ ឱ្យសន្និសីទលើកទី៩ របស់ UNCTAD ស្តីពីការគ្រប់គ្រងបំណុល ប្រព្រឹត្តទៅប្រកបដោយជោគជ័យថ្លៃថ្លា ។

**សូមអរគុណ!**

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number.......................................................................

**Keynote speech**

**H.E. Chea Chanto, Governor of the National Bank of Cambodia**

**9th UNCTAD Debt Management Conference**

**11 November 2013**

**Excellences, distinguished delegates, ladies and gentlemen […]**

It is a great honor and pleasure to join all of you to deliver the key note speech to the 9th UNCTAD Debt Management Conference. I would like to express my sincere thanks to UNCTAD for organizing this grand event on such timely and pressing topics pertaining to sovereign debt.

I have no doubt that this conference will provide an opportune occasion for all of the policy makers and debt managers from around the world to convene and deliberate over the most pressing challenges facing us during these uncertain times. I see that the diverse and global representation that we have today will provide us with much fuel and fodder of an interesting and informative exchange. I am looking forward to the debates that will take place in the coming days.

Let me take this opportunity to highlight and comment on the challenges posed to developing countries in maintaining sustainable debt in the current global economic environment and emphasize the need for countries and the international community to take measures that not only mitigate the impact and chance of future crises but also to consider developing instruments and mechanisms to address debt difficulties or crises should they arise.

**Debt sustainability in current global environment**

It is perhaps an understatement to say that the global economy has undergone significant volatility since the outbreak of the global financial crisis in 2008. The economic contraction that was accompanied by heavy and looming uncertainties created real and significant risks to the economic growth and debt sustainability of both developed and

developing countries. The weak economic recovery that we have witnessed thus far has proved to be a persistent challenge to developing countries, in particular with regard to achieving their development objectives.

The current global economic climate that we find ourselves in today is one that is characterized by slow growth and increasing interest-rate risk. The cheap sovereign financing that many countries have enjoyed in recent years may be ending as the interest rates on long-term bonds have begun to rise. This dynamic creates significant challenges for countries to manage and maintain sustainable debt levels. This is particularly true for developing countries, which have fewer sources of financing to draw from than developed countries. Moreover, developing countries have expended a significant degree of their fiscal buffers in recent years to respond and mitigate negative shocks stemming from the global financial and economic crisis. This has resulted in a diminishment of the policy space of many developing countries, which also poses a risk to the sustainability of their debt.

This scenario is further complicated by the uncertainties and low growth of advanced economies, which when coupled with ample global liquidity in search of higher returns, are also affecting the cost-risk trade-off that developing countries face in managing their debts. The abundance of global funds is compressing yield spreads making it easier for developing countries to access foreign capital. Low interest rates and the narrowing of bond spreads tend to favor a cost minimizing strategy by providing developing countries with a strong incentive to fund their debts on international markets, although there are risks to be managed in pursuing this strategy. The uncertainty surrounding the monetary policy stance of advanced economies, for instance, the timing and pace of their exit strategies, and the risks implied by their high levels of public debt could add to financial market volatility and suggest the greatest benefits from strategies aimed at minimizing risk.

## Risks posed to developing countries, particularly LDCs

The crisis has inflicted huge economic costs to countries, especially the developing ones. Prior to the crisis developing countries accumulated external reserves that enabled them to first withstand large capital outflows and then respond to the global recession with varying countercyclical policies. Thus far, developing countries as a group have been noticeably resilient to the negative effects of the crisis, owing to their active policy interventions and strong economic growth prior to the crisis. The transmission of the crisis to developing countries has

occurred through the real economy, which have manifested in contractions of trade, investment, remittances, and more recently in contractions of official development assistance. The weakening of these economic buffers, have made debt management an ever more challenging task.

Moreover LDCs have fewer opportunities and less sources of financing compared to other developing countries. With few exceptions, domestic debt markets are not sufficiently developed, especially in the long maturity segment, and the resources that can be raised are constrained by the limited amount of savings. Developing a domestic debt market is also costly in terms of financial and human resources. More importantly, domestic borrowing cannot fully replace external financing because LDCs must raise foreign exchange to buy foreign capital goods and equipment for investment projects. Current account imbalances suggest that foreign capital will continue to play an important role in the development of LDCs.

With the diminishing fiscal space to mitigate future shocks, developing countries are becoming increasingly vulnerable to external shocks and to the risk of renewed debt accumulation. This is particularly true for least developed countries (LDCs), a group to which Cambodia is a member.

Even though Cambodia's external debt burden is within relevant indicative thresholds under the baseline scenario, Cambodia, like other LDCs, remains sensitive and vulnerable to external shocks. The prolonged recovery from the global crisis makes maintaining the current debt ratio an arduous task for the Government.

**Going forward: global economic recovery, good debt strategies, missing links**

As the global economy continues to recover from the global financial crisis of 2008, it is clear that there is much work that lies ahead for both policy makers and debt managers as the road to normalization poses many risks and challenges for countries to overcome.

Recovery from the global financial and economic crisis has been slow thanks largely to the difficulty of rebalancing budgets (household, corporate and government) in advanced economies. In addition global economic growth is again decelerating and significant uncertainties and downside risks remain and pose potential threats to the recovery process. Of particular concern to many developing countries, a further slowdown in growth is likely to deepen the concerns surrounding

sovereign debt levels as well as threatening the provision of ODA. These trends have important implications for debt sustainability in developing countries. Low global growth and demand have negative effects on the export revenues of developing countries. In addition, the uncertain global economic outlook dampens investment and continues to weigh on aid budgets, thus raising concerns about the predictability of development assistance in the years to come.

Looking ahead, we must recognize that maintaining debt sustainability depends upon a multitude of factors that include not only future growth, but also borrowing conditions, terms of trade, foreign exchange risk, interest rate risk, among many other considerations. Policy makers and debt managers must remain vigilant in managing risk and responding difficulties in uncertain times. This is a formidable task that can be ameliorated through actions taken at the national and international level.

Of course, addressing problems before they arise is key to maintaining sustainable sovereign debt. At the country level I cannot emphasize enough the paramount importance for countries to adopt and design good debt strategies that take into consideration i) use of borrowed funds, ii) implementation of prudent and sound debt management, iii) choice of financing sources, iv) design of an effective debt strategy, and v) engagement in responsible sovereign lending and borrowing, to name a few. Beyond adopting effective strategies countries must also engage in active asset and liability management.

As a complement to effective national strategies, the international community must reinforce its efforts to address problems when they do arise. At present it is apparent that the missing link in the global financial architecture is the absence of a sovereign debt workout mechanism. This results in debt restructurings that are characterized as being "too little and too late". The general belief that collective action clause would be capable to solve the creditor coordination problems has proved to be terribly wrong in the recent litigation against Argentina. CACs do not constitute a complete bankruptcy mechanism alone. Debt crisis resolution in Greece is also a proof of the fact that the world is not well equipped to deal with sovereign debt crisis.

It is evident that the current ad hoc patch work of international arrangement is not one that can rapidly respond to crises when they arise. As a result count

## UNCTAD's work

UNCTAD’s analytical work on debt issues, in particular the UN Secretary-General’s report on debt issues prepared for the General Assembly, is an important contribution to the international debate on debt issues.

I am also pleased to learn that at the beginning of this year UNCTAD took the lead to set up a working group comprised of all stakeholders to examine the issues of a sovereign debt workout mechanism. The inclusive and transparent process bodes well for the initiative to come up with a framework more easily acceptable to both creditors and borrowers. With the global financial crisis and some recent events, more people have acknowledged that the lack of a debt workout mechanism is a missing link in the international financial architecture which has contributed to the “too little and too late” debt restructuring phenomenon. To redress this problem will require the participation and support of all stakeholders.

In addition, I would also like to express my appreciation for the good work of the DMFAS program. The focus of the Program is on the delivery of debt management assistance in its areas of comparative advantage, the "downstream" activities of debt management, at the national and, increasingly, subnational levels. The "downstream" activities include the maintenance of debt databases, debt data validation, debt operations, internal and external debt reporting, debt statistics and basic debt analysis, and building system links between debt management and other public finance management systems. They complement more "upstream" activities such as debt sustainability analysis supplied by other providers such as the World Bank and the IMF. Indeed, the Programme exemplifies UNCTAD's policy of cooperation with other organizations, systematically working in coordination with a broad range of providers of debt management technical assistance.

In closing, I would like to wish the 9$^{th}$ UNCTAD Debt Management Conference a resounding success.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីអបអរសាទរភាពជាដៃគូ
## រវាងធនាគារសហពាណិជ្ជ និង ធនាគារ E.SUN

សណ្ឋាគារសូហ្វីតែល ភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣

**សូមគោរព ៖**

- លោកឧកញ៉ា យាំ ស៊ុយសាំង ប្រធានក្រុមប្រឹក្សាភិបាលធនាគារសហពាណិជ្ជ
- លោក Yung-Jen Huang ស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាល E.SUN គ្រុប
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងពិធីភាពជាដៃគូរវាងធនាគារសហពាណិជ្ជនិងធនាគារ E.SUN ដែលជាធនាគាររបស់តៃវ៉ាន់លំដាប់អន្តរជាតិ។ តាងនាមឲ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមស្វាគមន៍និងអបអរសាទរយ៉ាងកក់ក្តៅ ចំពោះគណៈគ្រប់គ្រងធនាគារ E.SUN ដែលបានសម្រេចចិត្តចូលមកវិនិយោគនៅក្នុងទីផ្សារធនាគារនៅកម្ពុជាតាមរយៈការវិនិយោគរួមជាមួយធនាគារសហពាណិជ្ជ ។ ការវិនិយោគរបស់ធនាគារ E.SUN ក្នុងប្រទេសកម្ពុជានាពេលនេះ បានឆ្លុះបញ្ចាំងបន្ថែមទៀតពីជំនឿទុកចិត្ត ការគាំទ្រនិងការចូលរួមចំណែកកាន់តែច្រើនរបស់វិនិយោគិនបរទេសមកលើវិស័យធនាគារនៅកម្ពុជា ។

**ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនថា បន្ទាប់ពីប្រទេសកម្ពុជាទទួលបានសុខសន្តិភាពពេញលេញនៅឆ្នាំ១៩៩៩មក ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ រួមទាំងវិស័យធនាគារនិងហិរញ្ញវត្ថុ ។ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ច

កម្ពុជាសម្រេចបានកំណើនដ៏រឹងមាំជាមធ្យម ៨% ក្នុងនោះអត្រាកំណើនបានកើនដល់ពីរខ្ទង់គឺប្រមាណ ១១% ចាប់ពីឆ្នាំ២០០៤-២០០៧ ។ នៅឆ្នាំ២០១៣នេះ អត្រាកំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានដោយសុទិដ្ឋិនិយមថាមានកម្រិត ៧.៦% ដែលគាំទ្រដោយកំណើនរឹងមាំនៃការនាំចេញ ការរីកចម្រើននៃវិស័យកសិកម្ម ទេសចរណ៍ និងសំណង់ ។

ចំណែកវិស័យធនាគារនៅកម្ពុជាក៏មានការអភិវឌ្ឍរឹងមាំផងដែរ ទាំងផ្នែកវិសាលភាព ទំហំប្រតិបត្តិការ និងផលិតផល ដែលជាកម្លាំងចលករយ៉ាងសំខាន់ និងមានសក្តានុពលក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។ ប្រតិបត្តិការនិងផលិតផលហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកាន់តែមានការរីកចម្រើនជាលំដាប់ពាសពេញផ្ទៃប្រទេស ដែលឆ្លុះបញ្ចាំងអំពីជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារនៅកម្ពុជា ។ គិតត្រឹមឆមាសទី១ ក្នុងឆ្នាំ២០១៣ ប្រាក់បញ្ញើរបស់ប្រព័ន្ធធនាគារមានកំណើនប្រមាណ ២១% និងឥណទានកើនឡើងប្រមាណ ៣៤% បើធៀបនឹងឆមាសទី១ ក្នុង ឆ្នាំ២០១២ ។

ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងស្ថិរភាព និងភាពរឹងមាំនៃប្រព័ន្ធធនាគារក៏ដូចជាវិស័យហិរញ្ញវត្ថុ ដោយបានពិចារណា និងកែសម្រួលឡើងវិញនូវបទដ្ឋានគតិយុត្តិនានា ដែលមានស្រាប់ព្រមទាំងបង្កើតបទប្បញ្ញត្តិថ្មីៗ ដែលចាំបាច់ឲ្យស្របតាមស្តង់ដារអន្តរជាតិ និងស្ថានភាពរីកចម្រើនរបស់វិស័យធនាគារនៅកម្ពុជាផងដែរ ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការបន្តអនុវត្តគោលនយោ-បាយរូបិយវត្ថុនិងគោលនយោបាយអត្រាប្តូរប្រាក់ ប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្ន ដោយផ្អែកលើវឌ្ឍនភាពនៃសកម្មភាពសេដ្ឋកិច្ចជាតិ និងបម្រែបម្រួលសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក ។ ជាក់ស្តែង ស្ថានភាពអតិផរណាកំពុងស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ពោលគឺ អត្រាប្រមាណ ៤,២% ជាមធ្យមក្នុង ១ឆ្នាំ ។

**ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា**

ជាថ្មីម្តងទៀត ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំរបស់ធនាគារសហពាណិជ្ជ ដែលបានខិតខំប្រឹងប្រែងគ្រប់គ្រងនិងដឹកនាំធនាគារសហពាណិជ្ជឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងរយៈពេលជាង២០ឆ្នាំនៃប្រតិបត្តិការរបស់ខ្លួននៅកម្ពុជា។ ធនាគារសហពាណិជ្ជ ជាធនាគារមួយដែលគោរពច្បាប់និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជាបានល្អ ហើយក៏ជាធនាគារដែលបានផ្តល់សេវាល្អដល់អតិថិជននិងទទួលបានការគាំទ្រពីអតិថិជនយ៉ាងច្រើន ដែលឆ្លុះបញ្ចាំងពីការរួមចំណែកកសាងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារនៅកម្ពុជា ។

ម្យ៉ាងទៀតខ្ញុំសង្ឃឹមថា ធនាគារសហពាណិជ្ជដោយមានការចូលរួមពីធនាគារE.SUN ដែលធ្លាប់មានជំនាញនិងបទពិសោធន៍ល្អផ្នែកអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនឹងបន្តរួមចំណែកបន្ថែម

ទៀតក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា តាមរយៈការផ្តល់សេវា និងផលិតផលឲ្យកាន់តែទូលំទូលាយនិងសម្បូរបែប ជាពិសេស ការនាំមកនូវបទពិសោធន៍និងបច្ចេកវិទ្យាថ្មីៗ ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជនបន្ថែមទៀតនៅពេលបច្ចុប្បន្នក៏ដូចជានាពេលអនាគត ។

ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រីនិងអ្នកនាងកញ្ញា ភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញចូលរួម សូមមានសុខភាពល្អនិងទទួលបានជោគជ័យគ្រប់ភារកិច្ច ។ ខ្ញុំសូមជូនពរឲ្យធនាគារសហពាណិជ្ជទទួលបានការគាំទ្រនិងជំនឿទុកចិត្តបន្ថែមទៀតពីសាធារណជនជាតិនិងអន្តរជាតិនិងជូនពរថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកទាំងអស់ សូមបានជោគជ័យក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពនិងមាននិរន្តរភាពជារៀងរហូត ។

"Together and Further"

**សូមអរគុណ !**

Thank You!

ൖൖൖ✲ൖൖൖ

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number.............................................................

**Remarks**

**H.E. Chea Chanto, Governor of the National Bank of Cambodia**

**on the Occasion of UCB and E.SUN Bank Partnership Celebration Banquet**

**Sofitel Phnom Penh Hotel, 10$^{th}$ September 2013**

- **Okhna Yum Sui Sang, chairman of Union Commercial Bank**
- **Mr. Yung-Jen Huang, founder and chairman of E.SUN Group**
- **Excellencies, Distinguished Guests, Ladies and Gentlemen,**

Today I have a great pleasure to participate in the Partnership Celebration Banquet between Union Commercial Bank and E.SUN Commercial Bank, Ltd. which is a Taiwan-based international bank. On behalf of the National Bank of Cambodia, I would like to extend a warm welcome to and congratulate the management of E.SUN Bank for their decision to invest in Cambodia's banking sector, through investment with Union Commercial Bank. The investment of E.SUN Commercial Bank in Cambodia at this moment also reflects the confidence, the support, and the increasing contributions of foreign investors in the banking sector in Cambodia.

**Excellencies, Distinguished Guests, Ladies and Gentlemen**

Taking this opportunity, I would like to inform that after Cambodia achieved full peace in 1999 under the wise leadership of Samdech Akkak Moha Sena Padei Decho **Hun Sen**, Prime Minister of the Kingdom of Cambodia, all sectors, including banking and financial institutions, have gone through significant development. Over the last 10 years, Cambodia's economy has achieved strong growth of 8%, increasing to two digits approximately 11%

from 2004 to 2007. For this year, 2013, economic growth rate was estimated optimistically at 7.6%, which is supported by strong export growth, improved agriculture, tourism, and construction.

Banking sector's development in Cambodia has been strong in terms of scope and scale, which are the critical forces and have the potential for supporting economic growth. Financial operations and products of banking and financial institutions have continuously extended all over the country, reflecting the increasing public confidence on Cambodia's banking system. Compared with those of semester 1, 2012, total deposits and loans for semester 1, 2013 in the banking system have increased by approximately 21% and 34%, respectively.

The National Bank of Cambodia continue to stabilize and strengthen the banking system as well as the financial sector, through considering and amending existing regulatory frameworks, and issuing new regulations deemed necessary in compliance with international standards. Simultaneously, the National Bank of Cambodia has also been actively involved in maintaining macroeconomic stability, through continuously pursuing prudent and flexible monetary and foreign exchange policies, based on the development of national economic conditions, and global economic and financial changes. In fact, the yearly inflation rate has remained in the manageable level of 4.2% in average.

**Excellencies, Distinguished Guests, Ladies and Gentlemen**

Once again, I would like to express my high appreciation to the management of Union Commercial Bank for their efforts to lead and develop the bank in the 20 years of operation in Cambodia. The Union Commercial Bank has fully respected the regulation of the National Bank of Cambodia and also is a good banking services provider which has shown the contribution to build the confidence among the public on the banking system in Cambodia.

I hope that Union Commercial bank in partnership with E.SUN Commercial Bank who has a strong experience on developing the SME will contribute to

develop banking system in Cambodia through providing broader and more diversified banking services particularly new experiences and technology to meet customers' additional needs in the present and in the future

Finally, may I wish Excellencies, distinguished guests, ladies and gentlemen present here healthy and successful in all your duties. May I also wish the Union Commercial Bank to receive more support and confidence from the domestic and international clients and wish the management and all employees of Union Commercial Bank, Plc. successful in your business through effective and everlasting operations.

**"Together and Further"**

**Thank you!**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..............................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ថ្លែងក្នុងពិធីសម្ពោធ ដាក់ឱ្យដំណើរការជាផ្លូវការ

## អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺ

**នៅខេត្តកំពង់ស្ពឺ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៣**

ៜៜៜ✲ៜៜៜ

**សូមគោរព :**

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាភ្ញៀវកិត្តិយស ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានក្ដីសោមនស្សរីករាយជាអតិបរមាដោយបានមកចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការអគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺនាពេលនេះ ។ ពិធីរបស់យើងបានរៀបចំឡើងស្របពេលដែលប្រជាជនកម្ពុជាទូទាំងប្រទេសកំពុងបើកយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភាដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ ។ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺនេះ គឺជាសមិទ្ធផលសង្គមផ្នែកវិស័យធនាគារថ្មីមួយបន្ថែមទៀតសម្រាប់ប្រជាជន និងអាជ្ញាធរខេត្តកំពង់ស្ពឺប្រើប្រាស់ ។

សមិទ្ធផលនេះ គឺជាផ្នែកមួយនៃការរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងចូលរួមផ្សព្វផ្សាយចលនាប្រឡងប្រណាំងទីក្រុងស្អាតរបស់រាជរដ្ឋាភិបាលបន្ទាប់ពីសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសផ្សព្វផ្សាយចលនាប្រឡងប្រណាំងទីក្រុងស្អាតជាផ្លូវការកាលពីឆ្នាំ២០១២ កន្លងមក ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមអភិបាលខេត្តកំពង់ស្ពឺ ក្រុមប្រឹក្សាខេត្ត តំណាងមន្ទីរ-អង្គភាព និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដែលបានផ្ដល់កិច្ចសហប្រតិបត្តិការល្អនិងគាំទ្រការសាងសង់នេះ ។ ស្មារតីសហប្រតិបត្តិការល្អជាប្រពៃណីនេះ មានសារៈសំខាន់ណាស់ ជាគន្លឹះធ្វើឱ្យការងារយើងសម្រេចបានជោគជ័យនិងសមិទ្ធផលថ្មីៗបន្ថែម ទៀត ។

ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបាននូវសមិទ្ធផលយ៉ាងច្រើនជូនធនាគារជាតិនៃកម្ពុជា ហើយក៏បានរួមចំណែកអភិវឌ្ឍវិស័យ ធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើន និងបានទទួលការគាំទ្រ និងជំនឿទុកចិត្តពីសាធារណជនជាតិ អន្តរជាតិជាលំដាប់រហូតមកដល់ពេលនេះផងដែរ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ខ្ញុំសូមថ្លែងនូវការកោតសរសើរនិងសូមអបអរសាទរចំពោះស្នាដៃការងារនិងសមិទ្ធផលអភិវឌ្ឍរីកចម្រើននានានៅទូទាំងខេត្តកំពង់ស្ពឺនាពេលនេះ ។ ខេត្តកំពង់ស្ពឺជាខេត្តមួយមានសក្តានុពលសេដ្ឋកិច្ចទាំងផ្នែកកសិកម្ម កសិឧស្សាហកម្ម តំបន់អេកូទេសចរណ៍ដែលមានរមណីយដ្ឋានទេសចរណ៍ធម្មជាតិ ប្រវត្តិសាស្ត្រ និងវប្បធម៌ ហើយហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមជារូបវន្តក៏មានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ។ អគារទីស្នាក់ការថ្មីរបស់សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺនេះ មិនត្រឹមតែបង្ហាញពីការអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារ និងហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត និងសេដ្ឋកិច្ចសង្គមនៅខេត្តកំពង់ស្ពឺប៉ុណ្ណោះទេ ថែមទាំងបានរួមចំណែកជួយលើកសោភ័ណភាពខេត្តកំពង់ស្ពឺនិងចលនាប្រឡងប្រណាំងទីក្រុងស្អាតនៃខេត្តកំពង់ស្ពឺនាពេលនេះផងដែរ ។

តាមរយៈរបាយការណ៍របស់លោកនាយកសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺ ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា ការកសាងអគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺថ្មីនេះ ពិតជាបានឆ្លើយតបទៅនឹងការរីកចម្រើននៃសេដ្ឋកិច្ច និងតម្រូវការការងារចាំបាច់ក្នុងការគ្រប់គ្រង និងសម្របសម្រួលប្រតិបត្តិការរូបិយវត្ថុ ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត ។ អគារនេះត្រូវបានសាងសង់ឡើង ដោយបំពាក់ប្រព័ន្ធកុំព្យូទ័រនៅគ្រប់បន្ទប់ធ្វើការ ហើយផ្នែកខាងក្នុង និងខាងក្រៅអគារមានបំពាក់ប្រព័ន្ធការពារសុវត្ថិភាពទំនើប ។ ចាប់ពីថ្ងៃនេះទៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ និងសកម្មក្នុងការផ្តល់សេវារូបិយវត្ថុជូនមន្ទីរ អង្គភាពរបស់រដ្ឋ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងសាធារណជនទូទៅជួយសម្រួលដល់ប្រតិបត្តិការទូទាត់ពាណិជ្ជកម្មនិងធ្វើជាឃ្លាំងផ្ទុកទ្រព្យសម្បត្តិរដ្ឋនៅក្នុងខេត្ត ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថាសមិទ្ធផលនៃនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យប្រទេសកម្ពុជាបច្ចុប្បន្នមានសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គមនិងមានការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេស វិស័យសេដ្ឋកិច្ចជាតិបន្ទាប់ពី

វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក កំណើនសេដ្ឋកិច្ចជាតិបានងើបឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

ភាពអំណោយផលនេះ ដោយសារស្ថិរភាពនយោបាយល្អនិងការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលទ្រទ្រង់ដោយការរីកចម្រើននៃវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងសំណង់ ។ ជាក់ស្តែងនៅឆ្នាំ២០១២ កន្លងមកសេដ្ឋកិច្ចមានស្ថានភាពល្អប្រសើរ និងរក្សាបានអត្រាកំណើន ៧,៣% ។ ភាពល្អប្រសើរនេះ ដោយសាររាជរដ្ឋាភិបាលរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពថ្លៃ និងអត្រាប្តូរប្រាក់ ។ នៅឆ្នាំ២០១៣ តាមការព្យាកររបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចជាតិរំពឹងថា នឹងរក្សាបាននូវអត្រាកំណើនក្នុងរង្វង់៧% និងអត្រាអតិផរណាស្ថិតនៅក្នុងកម្រិតមួយទាបអាចគ្រប់គ្រងបាន ។

ចំណែកឯវិស័យធនាគារក៏មានការរីកចម្រើនយ៉ាងខ្លាំង ទាំងផ្នែកវិសាលភាព និងទំហំប្រតិបត្តិការ ។ បច្ចុប្បន្នប្រព័ន្ធធនាគារនៅកម្ពុជាមាន (១)-ធនាគារជាតិនៃកម្ពុជាដែលមានសាខានៅទូទាំងប្រទេស គឺជាអាជ្ញាធររូបិយវត្ថុជាតិ និងជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ *(២)-* គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ការិយាល័យព័ត៌មានឥណទាន និងអង្គការក្រៅរដ្ឋាភិបាលដែលបានធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ។

គិតត្រឹមខែមេសាឆ្នាំ២០១៣នេះការអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារអាចឆ្លុះបញ្ចាំងតាមរយៈ៖

១)-ការរីកចម្រើននៃបណ្តាញសាខា សេវា និងផលិតផលហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនៅទូទាំងប្រទេស

២)-ទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារកើនឡើងដល់ប្រមាណ១២ ពាន់លានដុល្លារអាមេរិកពោលគឺកើន ឡើងប្រមាណ ៣០% ធៀបនឹងខែមេសា ឆ្នាំ២០១២

៣)-ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារកើនឡើងដល់ប្រមាណ ៧ ពាន់លានដុល្លារអាមេរិកពោលគឺកើនឡើងប្រមាណ ២៦% ធៀបនឹងខែមេសា ឆ្នាំ២០១២ និង

៤)-ឥណទានចំពោះវិស័យឯកជនកើនឡើងដល់ប្រមាណ ៦ ពាន់លានដុល្លារអាមេរិកពោលគឺ កើនឡើងប្រមាណ ៣៥% ធៀបនឹងខែមេសា ឆ្នាំ២០១២ ។ ចំណែកឯឥណទានមិនដំណើរការ (NPL) ស្ថិតនៅកម្រិតទាបប្រហាក់ប្រហែលនឹងឆ្នាំ២០១២ គឺក្នុងរង្វង់៣% ។

សមិទ្ធផលរីកចម្រើនខាងលើនេះបញ្ជាក់ថា ប្រព័ន្ធធនាគារនៅកម្ពុជាមានភាពរឹងមាំនិងទទួលបានជំនឿទុកចិត្តពីសាធារណជននិងវិនិយោគិនជាតិអន្តរជាតិ ។ បច្ចុប្បន្នប្រព័ន្ធធនាគារបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការកៀរគរប្រាក់សញ្ជ័យដែលនៅទំនេរឱ្យចូល

ក្នុងប្រព័ន្ធដើម្បីយកទៅផ្តល់ឥណទានសម្រាប់ពង្រីកគម្រោងវិនិយោគនានាប្រកបដោយប្រសិទ្ធភាព ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ខ្ញុំសូមជម្រាបបន្តិចពីប្រវត្តិនៃការប្រែប្រួលមុខងារ និងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជាថា បន្ទាប់ពីប្រទេសកម្ពុជាយើងបានអនុវត្តសេដ្ឋកិច្ចទីផ្សារសេរីរួចមក យើងបានកែទម្រង់ប្រព័ន្ធធនាគារពីមួយថ្នាក់ (Mono Banking) ទៅជាប្រព័ន្ធធនាគារពីរថ្នាក់ (Two-Tier Banking) ហើយប្រព័ន្ធទាំងពីរនេះមានមុខងារ និងភារកិច្ចខុសគ្នា ។ កាលពីមុន ធនាគារជាតិនៃកម្ពុជា និងសាខាធនាគារជាតិនៃកម្ពុជាបានបំពេញមុខងារ និងភារកិច្ចជា ១)- អាជ្ញាធររូបិយវត្ថុ ២)- បេឡាថវិការដ្ឋាភិបាល និង ៣)- អ្នកផ្តល់សេវាកម្មធនាគារ ដូចជា ផ្តល់ឥណទាន ទទួលប្រាក់បញ្ញើនិងប្រព័ន្ធទូទាត់ ។ ការកែទម្រង់នេះបានផ្លាស់ប្តូរមុខងារនិងភារកិច្ចធនាគារជាតិនៃកម្ពុជានិងសាខារបស់ខ្លួនពីការអនុវត្តការងារដោយផ្ទាល់ទៅជាអ្នកគ្រប់គ្រងនិងដឹកនាំការងារវិញ ។ បច្ចុប្បន្នធនាគារជាតិនៃកម្ពុជានិងសាខាធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេសបំពេញមុខងារនិងភារកិច្ចជា៖

១/-បេឡារបស់រតនាគារជាតិ

២/-ធនាគាររបស់ធនាគារដែលមានសាខាធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេស ដើរតួនាទីជាអ្នកផ្តល់សេវាជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

៣/- ជាអ្នកបែងចែក គ្រប់គ្រង និងកែសម្រួលដល់ចរាចរណ៍ធនបត្រនៅទូទាំងប្រទេស

៤/- ជាឃ្លាំងទុកដាក់ទ្រព្យសម្បត្តិរបស់រដ្ឋប្រកបដោយសុវត្ថិភាព ។

ក្នុងការអនុវត្តមុខងារជាអាជ្ញាធររូបិយវត្ថុ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺនឹងដើរតួនាទីជាអ្នកសម្របសម្រួលចរាចរណ៍រូបិយវត្ថុជាតិនិងជាអ្នកផ្គត់ផ្គង់សាច់ប្រាក់ឱ្យរតនាគារខេត្តធនាគារពាណិជ្ជ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ព្រមទាំងអង្គការ ឬ ក្រុមហ៊ុន និងសាធារណជននានាសំដៅរក្សាស្ថិរភាពតម្លៃប្រាក់រៀល និងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលបន្ថែមទៀត ឆ្ពោះទៅរកការអនុវត្តកម្មវិធីពង្រឹងអន្តរការិយកម្មធនាគារ និងទីផ្សារហិរញ្ញវត្ថុនៅពេលអនាគត ។

ក្នុងការអនុវត្តមុខងារជាធនាគាររបស់រដ្ឋាភិបាលនិងជាធនាគាររបស់ធនាគារ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺនឹងទទួលបើកគណនីគ្រប់ប្រភេទឱ្យមន្ទីរ-អង្គភាពរដ្ឋ ធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីសម្រួលក្នុងការធ្វើចរាចរសាច់ប្រាក់ និងបម្រើសេវាជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុគ្រប់ប្រភេទ ។ ទាំងនេះ គឺជាតួនាទីសំខាន់របស់សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺ ។

ក្រៅពីនេះ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺនេះ មិនត្រឹមតែបង្ហាញពីភាពរឹងមាំនៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាដែលមានហេដ្ឋារចនាសម្ព័ន្ធដល់ជនបទប៉ុណ្ណោះទេថែមទាំងជួយលើកសោភ័ណភាពដល់ខេត្តកំពង់ស្ពឺទៀតផង ជាពិសេស អគារនេះនឹងធ្វើជាឃ្លាំងប្រាក់សម្រាប់

ផ្ទុកទ្រព្យសម្បត្តិរដ្ឋឱ្យមានសុវត្ថិភាព ។ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺក៏បំពេញតួនាទីជាភ្នាក់ងារជំរុញការប្រើប្រាស់ប្រាក់រៀលប្រចាំដែនដីផ្តល់សេវាកម្មធនាគារ និងហិរញ្ញវត្ថុនៅមូលដ្ឋាន និងធ្វើឱ្យប្រជាជនកាន់តែមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាកម្មធនាគារសម្រាប់យកទៅបង្កើនជីវភាពប្រចាំថ្ងៃរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

សរុបមកសមិទ្ធផលទាំងនេះ គឺជាសមិទ្ធផលរួមរបស់យើងទាំងអស់គ្នា ដែលកើតឡើងដោយស្មារតីសហការគ្នាល្អពីអាជ្ញាធរមានសមត្ថកិច្ចប្រចាំដែនដីគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាជីវករ ពាណិជ្ជករ និងប្រជាជនទូទៅនៅក្នុងខេត្តទាំងមូល។ សមិទ្ធផលថ្មីនេះត្រូវបានកសាងឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ទីផ្សារ និងរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ ហេតុដូច្នេះហើយទើបយើងចាត់ទុកសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺនេះ គឺជាសមិទ្ធផលរួម និងជាមោទនភាពរួមរបស់យើងទាំងអស់គ្នា ។ សូមរួមគ្នាជួយថែរក្សានិងប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យមានប្រសិទ្ធភាព និងស្ថិតស្ថិរយូរអង្វែងតរៀងទៅ ។

ខ្ញុំនៅតែមានជំនឿយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាតំណាងអាជ្ញាធរដែនដី មន្ទីរ-អង្គភាពនៅជុំវិញខេត្តកំពង់ស្ពឺទាំងអស់នៅតែបន្តស្មារតីសហការសាមគ្គីជាប្រពៃណីទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត។ ស្មារតីសាមគ្គីនិងការប្រើកម្លាំងសរុបបែបនេះ គឺជាកត្តាមួយសំខាន់បំផុតសម្រាប់កំណត់ជ័យជម្នះនិងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមលើគ្រប់វិស័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សូមមានសុខភាពល្អ ទទួលបានជ័យជម្នះគ្រប់ភារកិច្ច និងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ " **អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ស្ពឺ**" ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..........................................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការ ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣

**សូមគោរព :**

- ឯកឧត្តម Raja Saifful Ridzuwan តំណាងស្ថានទូតម៉ាឡេស៊ីប្រចាំកម្ពុជា
- លោក Tan Sri Quek Leng Chan ប្រធានក្រុមប្រឹក្សាភិបាល Hong Leong Group
- លោក Raymond Choong នាយក Hong Leong Financial Group និងជាប្រធានក្រុមប្រឹក្សាភិបាល ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមាដោយបានចូលរួមក្នុងពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ីដែលជាបុត្តសម្ព័ន្ធរបស់ធនាគារហុងលីអុងនៃប្រទេសម៉ាឡេស៊ី និងដែលបានបើកទីស្នាក់ការនៅភ្នំពេញនាពេលនេះ ។ តាងនាមឱ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមអបអរសាទរចំពោះគណៈគ្រប់គ្រងធនាគារ ហុង លីអុង ដែលខិតខំពង្រីកបណ្តាញសេវា សាខាប្រតិបត្តិការ អាជីវកម្មរបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការបើកជាបុត្តសម្ព័ន្ធរបស់ធនាគារនាពេលនេះ ។

ការបើកដាក់ឲ្យដំណើរការជាបុត្តសម្ព័ន្ធនៅកម្ពុជានាពេលនេះ បានឆ្លុះបញ្ចាំងពីកំណើនជំនឿទុកចិត្ត ការគាំទ្រនិងការរួមចំណែកកាន់តែច្រើនរបស់វិនិយោគិនបរទេស ជាពិសេស វិនិយោគិនម៉ាឡេស៊ីចំពោះទីផ្សារនៅកម្ពុជាដែលមាននិន្នាការកើនឡើងក្នុងការអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា ព្រមទាំងបានបង្ហាញពីស្មារតីសាមគ្គីភាព ការបន្តរឹតចំណងមិត្តភាព កិច្ចសហប្រតិបត្តិការរវាងប្រជាជននិងប្រទេសយើងទាំងពីរក៏ដូចជាក្នុងក្របខ័ណ្ឌអាស៊ាន ជាពិសេស បានរួមចំណែកដល់ការធ្វើសមា

ហរណកម្មវិស័យហិរញ្ញវត្ថុឱ្យកាន់តែស៊ីជម្រៅឆ្ពោះទៅសម្រេចគោលដៅនៃការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ ខាងមុខ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីមេត្រី**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនពីការអភិវឌ្ឍរីកចម្រើនសេដ្ឋកិច្ច និងវិស័យធនាគារកម្ពុជាថា ក្រោយពីកម្ពុជាទទួលបានសុខសន្តិភាពពេញលេញនៅឆ្នាំ១៩៩៩មក ប្រទេសកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ។ ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនដ៏រឹងមាំប្រមាណ ៨% ក្នុងនោះអត្រាកំណើនបានកើនដល់ពីរខ្ទង់ គឺប្រមាណ១១% ចាប់ពីឆ្នាំ២០០៤- ២០០៧ ។ នៅឆ្នាំ២០១៣នេះ អត្រាកំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានដោយសុទិដ្ឋិនិយមថាមានកម្រិត ៧,៦% ដែលគាំទ្រដោយកំណើនរឹងមាំនៃការនាំចេញ ការរីកចម្រើននៃវិស័យកសិកម្ម ទេសចរណ៍ និងសំណង់ ។ កំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះក៏អាចសម្រេចទៅបានដោយសារការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែង អត្រាអតិផរណាត្រូវបានស្ថិតនៅក្នុងកម្រិតទាបអាចគ្រប់គ្រងបានជាមធ្យមប្រមាណ ៥% ។

ចំណែកវិស័យធនាគារនៅកម្ពុជាវិញក៏មានការអភិវឌ្ឍយ៉ាងរឹងមាំផងដែរទាំងផ្នែកវិសាលភាពទំហំប្រតិបត្តិការនិងផលិតផល ។ នៅឆ្នាំ២០០៨-២០០៩ ថ្វីបើពិភពលោកបានជួបប្រទះនឹងវិបត្តិហិរញ្ញវត្ថុសកលក៏ដោយ ក៏វិស័យធនាគារនៅកម្ពុជាមានស្ថិរភាព និងមានការទាក់ទាញអ្នកវិនិយោគខាងអន្តរជាតិចូលមកវិនិយោគក្នុងវិស័យនេះថែមទៀតផង ។ ភាពទាក់ទាញនេះនៅតែបន្តរហូតដល់បច្ចុប្បន្ន ដូចមានការបើកធនាគារ ហុង លីអុង នេះជាឧទាហរណ៍ស្រាប់ ។

គ្រឹះស្ថានធនាគារនីមួយៗមានសុខភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈអត្រាឥណទានមិនដំណើរការទាបលទ្ធភាពទទួលបានប្រាក់ចំណេញខ្ពស់ ។ ដើម្បីគាំទ្រដល់ស្ថិរភាពនិងការអភិវឌ្ឍវិស័យធនាគារ ធនាគារជាតិនៃកម្ពុជាបានពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនិងហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុសំខាន់ៗ ដូចជា ប្រព័ន្ធទូទាត់ ការិយាល័យព័ត៌មានឥណទាន និងអភិវឌ្ឍទីផ្សាររូបិយវត្ថុ និងអន្តរធនាគារជាដើម ។

ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី បច្ចុប្បន្ននេះ ជាធនាគារខ្នាតអន្តរជាតិមួយមកពីប្រទេសម៉ាឡេស៊ីជាប់ចំណាត់ថ្នាក់ខ្ពស់បើគិតតាមទំហំទ្រព្យសកម្ម និងមានសាខាចំនួន ៣៣៤ សាខានៅតាមបណ្តាប្រទេសក្នុងតំបន់ ដូចជា ម៉ាឡេស៊ី សឹង្ហបុរី ហុងកុង និងវៀតណាមជាដើម ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ធនាគារនេះនឹងក្លាយជាដៃគូអភិវឌ្ឍន៍ដ៏ល្អមួយជាមួយរាជរដ្ឋាភិបាល

កម្ពុជា និងជាមួយធនាគារជាតិនៃកម្ពុជាក្នុងការអភិវឌ្ឍវិស័យធនាគារនៅកម្ពុជាឲ្យកាន់តែរីកចម្រើន និងប្រកបដោយស្ថិរភាពល្អ ស្របតាមការអភិវឌ្ឍរីកចំរើននៃសេដ្ឋកិច្ចជាតិ និងក្នុងតំបន់ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីមេត្រី**

ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវការកោតសរសើរនិងស្វាគមន៍ចំពោះថ្នាក់ដឹកនាំរបស់ធនាគារ ហុងលីអុង (ខេមបូឌា) ភីអិលស៊ី ហើយខ្ញុំសង្ឃឹមថា ធនាគារនឹងបន្តចូលរួមចំណែកក្នុងការពង្រឹងប្រតិបត្តិការឱ្យកាន់តែមានភាពរឹងមាំ តាមរយៈការនាំមកនូវបទពិសោធន៍ បច្ចេកវិទ្យា និងផលិតផលហិរញ្ញវត្ថុទំនើបថ្មីៗ ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជននៅពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគត ។ ខ្ញុំសូមជូនពរឱ្យធនាគារទទួលបានការគាំទ្រ និងជំនឿទុកចិត្តបន្ថែមទៀតពីសាធារណជនជាតិ និងអន្តរជាតិ ។

ទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញាជាភ្ញៀវកិត្តិយសទាំងអស់ សូមមានសុខភាពល្អនិងទទួលបានជោគជ័យគ្រប់ភារកិច្ច ។ ខ្ញុំសូមជូនពរថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកទាំងអស់របស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី សូមបានជោគជ័យក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាពជារៀងរហូត ។

**សូមអរគុណ!**

៚៚៚✲៙៙៙

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number.................................................................

# Remarks

## H.E. Chea Chanto, Governor of the National Bank of Cambodia
## In the occasion of Grand Opening Ceremony of Hong Leong Bank (Cambodia) Plc

Phnom Penh, 23rd August 2013

-His Excellency Raja Saifful Ridzuwan, Chargé d'Affaires of the Embassy of Malaysia to the Kingdom of Cambodia

-Tan Sri Quek Leng Chan, Chairman of the Board of Hong Leong Group

-Mr. Raymond Choong, Director of Hong Leong Financial Group, and Chairman of the Board of Hong Leong Bank (Cambodia) Plc

-Excellency, ladies and gentlemen

Today I have a great pleasure to participate in the Grand Opening Ceremony of Hong Leong Bank (Cambodia) Plc, an affiliate of Hong Leong Group Malaysia in Phnom Penh City. On behalf of the National Bank of Cambodia, I would like to express my sincerest and heartfelt congratulation to the management of Hong Leong Bank Malaysia for your tremendous efforts to expand business networking, services and operation to the Kingdom of Cambodia as witness by the launching of the bank's affiliate today.

The grand opening ceremony in Cambodia today reflects the increasing confidence, supports and participation of foreign investors' *especially* Malaysian investors in the development of banking sector in Cambodia as well as reflecting, friendship, and cooperation between people of the two nations in terms of ASEAN framework speed the process of economic and financial integration toward ASEAN Economic Community 2015.

**Excellency, ladies and gentlemen**

Taking this opportunity, I would like to say a bit about Cambodia's recent economic and banking sector development. After achieving a complete peace

and social stability throughout country since 1999, Cambodia under the wise leadership of Samdech Akkak Moha Sena Padei Techo Hun Sen, Prime Minister of the Kingdom of Cambodia, has developed in all sectors. In the past 10 years, Cambodia has managed to achieve strong growth averaging 8 percent per annum. Growth reached two-digit level at yearly average rate of 11 percent in 2004-2007. Optimistically, in 2013, growth rate has been estimated at 7.6 percent, supported by strong growth of exports, agriculture, tourism and construction. This strong growth is a result of macroeconomic stability. In fact, inflation is maintained at a manageable level of 5 percent on average.

The banking sector in Cambodia has been developing soundly, in terms of scope, balance sheet and products. In 2008-2009, despite the global financial crisis, Cambodia's banking sector remained stable and was attracting international investors to come on board. The sector has continued to attract investors, and today we have Hong Leong Bank (Cambodia) Plc as an example.

The healthiness of each banking institution is reflected by low non-performing loan rates and high profitability. To support the banking sector to develop on a stable basis, the National Bank of Cambodia has strengthened legal and regulatory framework, major financial market infrastructure such as payment system and credit bureau, and developed money/interbank markets.

Hong Leong Bank (Cambodia) Plc, an affiliate of international bank from Malaysia, ranks among the top in term of assets size and having 335 branch networks in many countries in the region such as Malaysia, Singapore, Hong Kong, and Vietnam. I strongly believe that the Bank will become a good development partner of the Royal Government of Cambodia in general and a good partner of the National Bank of Cambodia in particular in sustaining and developing the banking sector in line with economic development of the country and of the region.

**Excellency, ladies and gentlemen**

Once again, I would like to express my highest appreciation and welcome to the management of Hong Leong Bank (Cambodia) Plc and hope that the bank will actively participate in strengthening banking sector operation through bringing new experiences, technology, and products and services to satisfy

customers' need currently and in the future. May I wish the bank to obtain further support from the public domestically and internationally.

Finally, may I wish Excellency, distinguish guests, ladies and gentlemen good health and success in all endeavors. I also wish the management and staff of Hong Leong Bank (Cambodia) Plc success in your business.

Thank you!

***បកប្រែក្រៅផ្លូវការ***

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល ធនាគារជាតិ នៃ កម្ពុជា
# ថ្លែងក្នុងពិធីបើកសិក្ខាសាលាលើកទី៧ នៃមជ្ឈមណ្ឌល SEACEN BOJ ស្តីពី
# សេរីភាវូបនីយកម្មគណនីមូលធន និងការគ្រប់គ្រងលំហូរមូលធន

**សៀមរាប ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៣**

ឈឈឈ✲៙៙៙

**សូមគោរព ៖**

- **លោក Hoo-Kyu Rhu, នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលស៊ាសិន**
- **លោក Soichiro Mitsuno អនុប្រធាននាយកដ្ឋានអន្តរជាតិនៃធនាគារជប៉ុនផ្នែកជញ្ជីងទូទាត់**
- **លោកបណ្ឌិត Diwa Guinigundo ទេសាភិបាលរង Bangko Sentral ng Pilipinas,**
- **វាគ្មិនកិត្តិយស**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាជាទីមេត្រី**

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដោយបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលាលើកទី៧ ស្តីពីសេរីភាវូបនីយកម្មគណនីមូលធន និងការគ្រប់គ្រងលំហូរមូលធនរបស់មជ្ឈមណ្ឌលស៊ាសិន ដែលសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការរូបិយវត្ថុក្នុងតំបន់អាស៊ីរបស់ធនាគារកណ្តាលជប៉ុននៅក្នុងខេត្តសៀមរាប ។

តាងនាមឲ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះវាគ្មិនកិត្តិយស គណៈប្រតិភូ និងអ្នកចូលរួមមកពីបណ្តាធនាគារកណ្តាល និងអាជ្ញាធររូបិយវត្ថុជាគ្រួសារនៃមជ្ឈមណ្ឌលស៊ាសិនទាំងអស់ ដែលបានអញ្ជើញមកដល់ព្រះរាជាណាចក្រកម្ពុជា និងជាពិសេសបានមកដល់រាជធានីអង្គរ ដែលជាទីក្រុងបុរាណរបស់យើងខ្ញុំ ។ ខ្ញុំមានសេចក្តីសោមនស្សរីករាយសូមថ្លែងអំណរគុណចំពោះ លោក Rhu ព្រមទាំងមជ្ឈមណ្ឌលស៊ាសិន និងលោក Mitsuno ព្រមទាំងមជ្ឈមណ្ឌលសហប្រតិបត្តិការរូបិយវត្ថុក្នុងតំបន់អាស៊ីនៃធនាគារកណ្តាលជប៉ុន និងវាគ្មិនទាំងអស់ ដែលបានចូលរួមក្នុងសិក្ខាសាលានេះ ។

ក្នុងបរិបទបច្ចុប្បន្ន សិក្ខាសាលានេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់តំណាងមកពីបណ្តាប្រទេសជាសមាជិកស៊ាសិន ដើម្បីបង្កើនចំណេះដឹងផ្នែកវិភាគ តាមរយៈការសិក្សាពីវាគ្មិនរបស់យើងលើប្រធានបទស្តីពី លំហូរមូលធន និងផលប៉ះពាល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សិក្ខាសាលានេះ ជាមូលដ្ឋានមួយផ្តល់ការយល់ដឹងយ៉ាងល្អប្រសើរសម្រាប់សិក្ខាកាម និងអ្នកបង្កើតនយោបាយទាំងអស់ ដើម្បីសម្រេចគោលដៅចម្បងពីររបស់ធនាគារកណ្តាល និងអាជ្ញាធររូបិយវត្ថុគឺ អតិផរណាទាប ហើយមានស្ថិរភាព និងស្ថិរភាពហិរញ្ញវត្ថុ ។

**ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោក លោកស្រី និងនាងកញ្ញា**

